Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 1

# តើអធិដ្ឋានជាអ្វី?

គ្រីស្ទបរិស័ទរួមរស់ជាមួយព្រះយេស៊ូ ដែលគង់នៅជាមួយខ្លួន ។ ហេតុដូច្នេះហើយទើបគ្រីស្ទបរិស័ទតែងនិយាយសន្ទនាជាមួយព្រះអង្គគ្រប់ពេលវេលា ដូចមិត្តសម្លាញ់សន្ទនាជាមួយមិត្តដែលខ្លួនស្រឡាញ់យ៉ាងជិតស្និទ្ធដែរ ។

ម្យ៉ាងទៀត គ្រីស្ទបរិស័ទរួមជាមួយព្រះយេស៊ូ ដែលសន្ទនាជាមួយព្រះបិតា ដូចកូនតែងនិយាយរឿងរ៉ាវផ្សេងៗជាមួយឪពុកម្ដាយ ។ «ព្រះវិញ្ញាណរបស់ព្រះយេស៊ូរួមជាមួយវិញ្ញាណយើងដើម្បីបន្លឺសម្លេងថា៖ ”ឪ! ឱព្រះបិតាអើយ!” » (រ៉ូម ៨.១៥) ។

ពាក្យសន្ទនានេះ គ្រីស្ទបរិស័ទសន្មតថា «**អធិដ្ឋាន**» ។ សៀវភៅនេះមានពាក្យអធិដ្ឋានល្អៗជាច្រើន ។ យើងសង្ឃឹមថា ពាក្យអធិដ្ឋានទាំងនេះ ជួយឲ្យបងប្អូនរួមជាមួយព្រះយេស៊ូ និងសន្ទនាជាមួយព្រះបិតាបាន ។

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 2



# ១ អធិដ្ឋានពេលភ្ញាក់ពីដំណេក



## សូមថ្វាយខ្លួន

ខ្ញុំសូមថ្វាយកាយ វាចា ចិត្ត ចំពោះព្រះជាអម្ចាស់
សូមព្រះអង្គគង់ជាមួយខ្ញុំ  ជួយការពារខ្ញុំគ្រប់ពេលវេលា
ឲ្យខ្ញុំប្រព្រឹត្តតែកិច្ចការដែលគាប់ព្រះហឫទ័យព្រះអង្គផង ។

**********

បពិត្រព្រះបិតារបស់មនុស្សទាំងអស់
កូនសូមផ្ញើជីវិតលើព្រះអង្គ ទាំងអរព្រះគុណផង ។
សូមព្រះអង្គប្រោសឲ្យកូនលែងសង្ស័យ
សូមប្រោសឲ្យកូនបន្តពន្លឺនៃសេចក្ដីសង្ឃឹម
ទៅអ្នកដទៃតាមការរស់នៅរបស់កូនផង ។  អាម៉ែន ។

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 3



សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។
បពិត្រព្រះបិតាជាអម្ចាស់
សូមព្រះមេត្តាបើកបបូរមាត់ ឲ្យខ្ញុំច្រៀងលើកតម្កើង
ពីស្នាព្រះហស្ដដ៏អស្ចារ្យរបស់ព្រះអង្គ ។

***********

បពិត្រព្រះយេស៊ូជាអម្ចាស់!
ក្នុងថ្ងៃនេះ ខ្ញុំចង់បានដូចព្រះអង្គ ។
សូមប្រោសឲ្យខ្ញុំប្រព្រឹត្តកិច្ចការទាំងអស់
តាមព្រះអង្គសព្វព្រះហឫទ័យ ។
សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

***********

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 4



# ២ អធិដ្ឋានពេលព្រឹក



Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 5



សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

## ឱ! ព្រះបិតាយើងខ្ញុំ

ឱ! ព្រះបិតាយើងខ្ញុំ
ដែលគង់នៅស្ថានបរមសុខអើយ!
សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ
សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់
សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី
ដូចនៅស្ថានបរមសុខដែរ ។

សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ ។
សូមអត់ទោសឲ្យយើងខ្ញុំ
ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក
ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ ។
សូមកុំបណ្តោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ
តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាច ។

២

## សូមអង្វរព្រះនាងម៉ារី

បពិត្រព្រះនាងម៉ារី ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមព្រះនាងមានអំណរសប្បាយ ព្រះអង្គគង់ជាមួយនាង
ព្រះអង្គបានប្រទានពរដល់នាងលើសស្ត្រីទាំងឡាយ
ហើយទ្រង់ក៏ប្រទានពរដល់បុត្រព្រះនាងដែរ ។

ឱ! សន្តីម៉ារី ជាព្រះមាតាព្រះអម្ចាស់
សូមជួយអង្វរព្រះអង្គឲ្យយើងខ្ញុំជាអ្នកបាប
នៅពេលឥឡូវនេះហើយនៅពេលស្លាប់ផង ។ អាម៉ែន ។

## សូមកោតសរសើរ

សូមកោតសរសើរព្រះបិតា
ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលព្រះអង្គគង់នៅតាំងពីដើមរៀងមក
ហើយជាដរាបតរៀងទៅ ។ អាម៉ែន ។

## សូមអរព្រះគុណព្រះបិតា

សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

- ឱ! ព្រះបិតា យើងខ្ញុំសូមអរព្រះគុណព្រះអង្គ! ចំពោះពិភពលោកយើងដ៏ល្អប្រណិត ។
- កូនសូមអរព្រះគុណព្រះអង្គ! ដែលប្រទានឲ្យមានព្រះអាទិត្យរះឡើង និងលិចទៅវិញ ។
- កូនសូមអរព្រះគុណព្រះអង្គ! ដែលប្រទានឲ្យមានព្រះច័ន្ទ និងផ្កាយទាំងឡាយ ។
- សូមព្រះអម្ចាស់ប្រទាន ឲ្យយើងខ្ញុំមានចិត្តស្រឡាញ់តែព្រះអង្គ និងធ្វើអ្វីៗតាមដែលព្រះអង្គសព្វព្រះហឫទ័យ ។
- សូមប្រោសប្រទាន ឲ្យខ្ញុំស្រឡាញ់ព្រះអង្គអស់ពីចិត្ត ច្រើនជាងពីម្សិលម៉ិញ និងតិចជាងថ្ងៃស្អែក ហើយនេះគឺជាព្រះអំណោយទានដ៏ប្រសើរបំផុត!

«ឱ! ព្រះបិតា ...បពិត្រព្រះនាងម៉ារី ... សូមកោតសរសើរ...»

២

## សូមអង្វរសម្រាប់ថ្ងៃថ្មី

- បពិត្រព្រះបិតាដ៏សប្បុរស ថ្ងៃថ្មីចាប់ផ្តើមហើយ! សូមប្រោសខ្ញុំឲ្យរួមជាមួយអ្នកឯទៀតៗ កសាងពិភពលោកថ្មីប្រកបដោយមនុស្សធម៌ ។
- សូមប្រោសឲ្យខ្ញុំមានចិត្តក្លាហាន សុខចិត្តទៅទាក់ទងនឹងអ្នកដទៃ ឲ្យខ្ញុំញញឹមដាក់គេ និងឲ្យខ្ញុំបានទទួលស្នាមញញឹមពីគេដែរ
- សូមឲ្យខ្ញុំជម្រាបសួរគេ និងឲ្យបានទទួលពាក្យជម្រាបសួរពីគេវិញដែរ ។
- សូមប្រោសឲ្យខ្ញុំនិយាយលេងជាមួយអ្នកដទៃ និងផ្តល់អំណរសប្បាយដែលមកពីព្រះអង្គ សាយភាយដល់អ្នកទាំងនោះផង ។
- សូមឲ្យអ្នកដទៃមានអំណរសប្បាយដោយសារខ្ញុំ ហើយសូមឲ្យខ្ញុំមានអំណរសប្បាយ ដោយសារបងប្អូនទាំងនោះដែរ ។

«ឱ! ព្រះបិតា...បពិត្រព្រះនាងម៉ារី... សូមកោតសរសើរ...»

## ព្រះអម្ចាស់ប្រទានពរដល់អស់អ្នកកើតទុក្ខព្រួយ

ឱ ព្រះអម្ចាស់អើយ! សូមព្រះអង្គប្រទានពរ
ដល់អស់អ្នកដែលរងទុក្ខលំបាកយ៉ាងខ្លាំង
ដល់អស់អ្នកដែលរស់នៅគ្មានញាតិជាទីពឹង
ដល់អស់អ្នកដែលធ្វើការហត់នឿយគ្មានពេលសម្រាក
ដល់អស់អ្នកដែលមិនហ៊ាននិយាយពីទុក្ខលំបាករបស់ខ្លួន ។

*ឱ ព្រះអម្ចាស់អើយ! សូមព្រះអង្គប្រទានពរ*
*ដល់អស់អ្នកស្លាប់ដោយអត់អាហារ*
*សូមព្រះអង្គទទួលគាត់ឲ្យចូលក្នុងព្រះរាជ្យព្រះអង្គផង ។*

ឱ ព្រះអម្ចាស់អើយ! សូមព្រះអង្គ
កុំឲ្យនរណាម្នាក់នៅលើផែនដីនេះ កើតទុក្ខព្រួយឡើយ ។

*ឱ ព្រះអម្ចាស់អើយ! សូមព្រះអង្គប្រទានពរ*
*ដល់អស់អ្នកដែលមានអំណរសប្បាយដែរ*
*សូមព្រះអង្គការពារពួកគាត់ផង ។*

ចំពោះកូនវិញ ព្រះអង្គមិនបាច់រំដោះកូន
ឲ្យរួចផុតពីទុក្ខព្រួយទេ តែសូមព្រះអង្គប្រទានកម្លាំងឲ្យកូន
អាចស៊ូទ្រាំនឹងទុក្ខព្រួយទាំងនោះវិញ ។

សន្ដី អេឌីត ស្ដាំង

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 10

# ៣ អធិដ្ឋានពេលល្ងាច

៣



Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 11



## សូមថ្វាយកិច្ចការទាំងអស់របស់សត្វលោក

សូមថ្វាយបង្គំព្រះបិតា

ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

- បពិត្រព្រះបិតាយើងខ្ញុំ !
  ព្រះអង្គមិនមែនជាព្រះបិតារបស់ខ្ញុំតែម្នាក់ឯងនោះទេ
  ដ្បិតព្រះអង្គគង់នៅក្នុងជម្រៅចិត្តខ្ញុំ
  ហើយក៏គង់នៅក្នុងជម្រៅចិត្តមនុស្សគ្រប់ៗរូបដែរ
  ព្រះអង្គសង់ព្រះដំណាក់នៅគ្រប់ទីកន្លែង ។
- រាល់ល្ងាច ខ្ញុំនៅស្ងៀមស្ងាត់
  ដើម្បីអធិដ្ឋានឆ្ពោះទៅព្រះអង្គ
  ខ្ញុំសូមថ្វាយកិច្ចការទាំងអស់របស់សត្វលោក
  និងសំណើចក្អាកក្អាយទាំងប៉ុន្មាន ។
  ខ្ញុំសូមបន្លឺសូរស័ព្ទតែមួយថា៖

« ឱ! ព្រះបិតា ...បពិត្រព្រះនាងម៉ារី ... សូមកោតសរសើរ... »

## សូមប្រទានសេចក្ដីសុខសាន្ត

៣

សូមថ្វាយបង្គំព្រះបិតា ... អាម៉ែន ។

- បពិត្រព្រះអម្ចាស់ ក្រោយពីចប់ការងារពេញមួយថ្ងៃ ខ្ញុំសូមនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ។
- សូមទ្រង់ព្រះមេត្តាទទួលអ្វីៗដ៏ល្អ ដែលខ្ញុំបានប្រព្រឹត្តក្នុងថ្ងៃនេះ សូមអត់ទោសចំពោះអំពើអាក្រក់ដែលខ្ញុំបានប្រព្រឹត្តដែរ ។
- សូមព្រះអង្គល្អងលោមអស់បងប្អូន ដែលឈឺចាប់ដោយសារខ្ញុំ ។
- សូមព្រះអង្គប្រទានសេចក្ដីសុខសាន្ត ដល់អស់បងប្អូន ដែលរិះគន់ ដាក់ទោសខ្ញុំ និងចំពោះអស់បងប្អូនដែលបានរាប់អានខ្ញុំដែរ ។ សូមប្រោសប្រទានព្រះវិញ្ញាណរបស់ព្រះអង្គ ថ្នាក់ថ្នមគេ ។
- នៅយប់នេះ ! សូមព្រះអង្គប្រោសប្រណីដល់យើងខ្ញុំទាំងអស់គ្នា ឲ្យមានសេចក្ដីសុខសាន្ត ។
- សូមឲ្យយើងខ្ញុំទទួលទានដំណេកលង់លក់ស្រួល ក្នុងពន្លឺរបស់ព្រះអង្គ ។ អាម៉ែន ។ សូមកោតសរសើរ ...

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 13





## សូមព្រះយេស៊ូគង់នៅជាមួយខ្ញុំ

សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

- បពិត្រព្រះបិតាដែលគង់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត
  កូនសូមអរព្រះគុណព្រះអង្គ
  ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
  ជាព្រះបុត្រាជាទីស្រឡាញ់របស់ព្រះអង្គ
  ដែលគង់នៅជាមួយកូនក្នុងថ្ងៃនេះ ។
- កូនសូមផ្ញើកាយ និងអ្វីៗទាំងអស់
  ក្នុងព្រះហស្តរបស់ព្រះអង្គ ។
  សូមទ្រង់ចាត់ទេវទូតមកការពារកូន
  កុំឲ្យមារកំណាចមានអំណាចលើកូនឡើយ ។ អាម៉ែន ។
- រួមជាមួយព្រះយេស៊ូគ្រីស្ត
  និងគ្រីស្តបរិស័ទទូទាំងពិភពលោក កូនហ៊ានសូត្រថា៖
  «ឱ! ព្រះបិតាយើងខ្ញុំ ...»(ទំព័រ ៥)

៣

## ព្រះបិតាជាជម្រករបស់ខ្ញុំ

សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

- បពិត្រព្រះអម្ចាស់ !
ព្រះអង្គជាជម្រកដ៏រឹងមាំរបស់ខ្ញុំ
សូមព្រះអង្គយាងមកសង្គ្រោះខ្ញុំ
សូមព្រះអង្គប្រទានពរ
ដល់អស់អ្នកដែលមានចិត្តស្រឡាញ់អ្នកដទៃ
និងដល់អស់អ្នកដែលគ្មាននរណាស្រឡាញ់គេផងដែរ ។

- រួមជាមួយព្រះយេស៊ូគ្រីស្ត
និងគ្រីស្តបរិស័ទទូទាំងពិភពលោក ខ្ញុំបានសូត្រថា៖
«ឱ! ព្រះបិតាយើងខ្ញុំ ...»(ទំព័រ ៥)
«បពិត្រព្រះនាងម៉ារី ... សូមកោតសរសើរ...» (ទំព័រ ៦)

## ព្រះបិតាគង់នៅជាមួយខ្ញុំ

- យប់មកដល់ហើយ!
  បពិត្រព្រះបិតា ព្រះអង្គជ្រាបច្បាស់ហើយថា
  ថ្ងៃនេះ ខ្ញុំជួបបញ្ហាជាច្រើន
  ខ្ញុំបានទទួលភ្ញៀវ ហើយក៏បានរំលែកសុខទុក្ខពីគេ
  ខ្ញុំបានស្តាប់ ហើយក៏បាននិយាយជាមួយគេដែរ ។
  ពេលនោះ ព្រះអង្គគង់នៅជាមួយខ្ញុំ
  គឺព្រះអង្គបានទទួលគេតាមខ្ញុំ ។
- សូមអរព្រះគុណព្រះបិតា ដែលគង់នៅជាមួយខ្ញុំ
  មានតែព្រះអង្គទេដែលទ្រង់ជ្រាបគ្រប់កិច្ចការទាំងអស់ ។
- កូនសូមទូលថ្វាយព្រះអង្គនូវពាក្យចុងក្រោយ ក្នុងថ្ងៃនេះ
  ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
  និងគ្រីស្តបរិស័ទទូទាំងពិភពលោក ដោយសូត្រថា៖

«ឱ! ព្រះបិតាយើងខ្ញុំ ...»(ទំព័រ ៥)

## អធិដ្ឋានរួមក្នុងគ្រួសារ

៣ * មានមេគ្រួសារម្នាក់ជាអ្នកណែនាំអធិដ្ឋាន (ឧបមា ឪពុក ឬម្ដាយ ឬបង...) ។ កូនម្នាក់ផុតទៀន ហើយទាំងអស់គ្នាចាប់ផ្ដើមលើកដៃប្រណម្យ៖

- សូមថ្វាយបង្គំព្រះបិតា
  ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

* មេគ្រួសារ៖ «សូមតាំងចិត្តឆ្ពោះទៅព្រះអម្ចាស់»

- បពិត្រព្រះបិតាជាអម្ចាស់ !
  ព្រះអង្គត្រាស់ហៅយើងខ្ញុំឲ្យស្គាល់
  និងស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើងៗជារៀងរាល់ថ្ងៃ
  ព្រះអង្គក៏ប្រោសយើងខ្ញុំឲ្យជួបជុំគ្នា
  រួមជាមួយព្រះអង្គដែរ ។
- សូមទ្រង់ព្រះមេត្តាប្រោសឲ្យយើងខ្ញុំចេះស្ដាប់
  និងធ្វើតាមព្រះបន្ទូលព្រះអង្គ ដូចសន្តបុគ្គលទាំងឡាយ
  ដែលធ្វើតាមព្រះហឫទ័យព្រះអង្គដែរ ។
- យើងខ្ញុំសូមអង្វរសន្តបុគ្គលទាំងឡាយ
  ដែលរស់នៅមុនយើងខ្ញុំ ដែលជួយឲ្យយើងខ្ញុំមានជំនឿ
  សូមអង្វរព្រះបិតាឲ្យយើងខ្ញុំ
  សូមថែរក្សាក្រុមគ្រួសារយើងខ្ញុំផង ។

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 17



* មេគ្រួសារអង្វរសន្តបុគ្គល៖

- សូមសន្តីម៉ារីជាព្រះមាតាព្រះយេស៊ូ និងសន្ត:យ៉ូសែប ជាស្វាមី

*បន្ទរ៖ «សូមជួយអង្វរព្រះអម្ចាស់ឲ្យយើងខ្ញុំផង»*

- សូមសន្តទេវទូត មីកាអែល សន្តទេវទូត កាព្រីអែល
  សន្តទេវទូត រ៉ាហ្វាអែល និងសន្តទេវទូតទាំងឡាយ *បន្ទរ*
- សូមសន្តីអេលីហ្សាប៊ែត និងសន្ត:សាការី *បន្ទរ*
- សូមសន្ត:យ៉ូហានបាទីស្ត *បន្ទរ*
- សូមសន្ត:សិលា និងសន្ត:ប៉ូល *បន្ទរ*
- សូមអស់គ្រីស្តទូតទាំងឡាយ *បន្ទរ*

* ម្នាក់ៗអាចអង្វរដល់សន្ត: សន្តីរបស់ខ្លួន ព្រមទាំងដល់ជូនតា ឬ នរណាម្នាក់ ដែលចែកឋានទៅហើយបានដែរ ។ នៅពេលចុងក្រោយមេគ្រួសារសូត្រថា៖

- សូមសន្តបុគ្គលទាំងអស់
  ជួយអង្វរព្រះអម្ចាស់ឲ្យយើងខ្ញុំផង ។
- ឱ! ព្រះបិតា ... ។
- សូមថ្វាយបង្គំព្រះបិតា
  ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

## សូមអរព្រះគុណព្រះបិតា

៣ - កូនសូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

- បពិត្រព្រះបិតាជាអម្ចាស់
ថ្ងៃនេះ កូនសូមអរព្រះគុណ ព្រះអង្គចំពោះ(ឪពុក ឬម្តាយ បងប្អូន មិត្ត ...) ដែលបាន( ធ្វើមួយដ៏ល្អដល់យើង)

- កូនសូមព្រះអង្គលើកលែងទោសឲ្យកូន
ដែលបានប្រព្រឹត្តកំហុសចំពោះ (.....................)

- កូនសូមទូលព្រះអង្គអំពី (មិត្តរបស់ខ្ញុំ ...)
ដែលបាន( ធ្វើមួយដ៏ល្អដល់យើង)

- ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
និងគ្រីស្តបរិស័ទទូទាំងពិភពលោក កូនសូមសូត្រថា៖
« ឱ! ព្រះបិតាយើងខ្ញុំ ...(ទំព័រ ៥)
បពិត្រព្រះនាងម៉ារី ... (ទំព័រ ៦)
សូមកោតសរសើរព្រះបិតា ... អាម៉ែន ។ »

## **សូមព្រះអម្ចាស់បំភ្លឺចិត្តគំនិតកូន!**

*- បពិត្រព្រះអម្ចាស់ជាម្ចាស់របស់កូន!*
*កូនមើលមិនឃើញផ្លូវដែលនៅពីខាងមុខ*
*កូនមិនអាចរៀបចំខ្លួនឲ្យបានត្រឹមត្រូវ*
*កូនមិនដឹងថា កូនត្រូវទៅទីណាឡើយ ។*

- កូនស្គាល់ខ្លួនឯងមិនច្បាស់ទេ នៅពេលកូននិយាយថា
ជឿ និងដើរតាមព្រះអង្គ ប្រហែលពេលនោះ
កូនមិនបានប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គនោះទេ ។

*- កូនសូមផ្ញើជីវិតលើព្រះអង្គ*
*ហើយកូនក៏ចង់ឲ្យគាប់ព្រះហឫទ័យព្រះអង្គដែរ ។*
*កូនសង្ឃឹមថា អ្វីៗដែលកូនបានប្រព្រឹត្ត*
*នោះនឹងគាប់ព្រះហឫទ័យព្រះអង្គ ។*

- កូនជឿទុកចិត្តលើព្រះអង្គជារៀងរហូត
ទោះបីកូនអស់សង្ឃឹមក្ដី កូនដើរក្នុងទីងងឹតក្ដី
កូនមិនខ្លាចអ្វីសោះ ព្រោះព្រះអង្គគង់នៅជាមួយកូនជានិច្ច
ព្រះអង្គមិនទុកកូនបោលក្នុងសភាពគ្រោះថ្នាក់ទេ ។*ថូម៉ាសមែរតុន*

«-បពិត្រព្រះនាងម៉ារី ... - សូមកោតសរសើរ...»(ទំព័រ ៦)

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 20

# ៤ អធិដ្ឋាន
# ពេលទទួលទានអាហារ

៤



សូមព្រះជាម្ចាស់ប្រទានពរលើអាហារ
ដែលយើងរាល់គ្នានឹងទទួលទាន
ហើយសូមប្រទានឲ្យយើង និងមនុស្សទាំងឡាយ ។

**********

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 21





សូមអរព្រះគុណព្រះជាអម្ចាស់
ចំពោះអាហារថ្ងៃនេះ ហើយសូមប្រទានឲ្យយើង
និងមនុស្សទាំងឡាយ បានបរិភោគរាល់ថ្ងៃ ។

✻✻✻✻✻✻✻✻✻✻

អស់មួយជីវិត ខ្ញុំច្រៀងសរសើរព្រះយេស៊ូគ្រីស្ត
ឱ! ព្រះម្ចាស់អើយ មួយជីវិតខ្ញុំ ខ្ញុំលើកតម្កើងតែព្រះនាមនេះ ។

✻✻✻✻✻✻✻✻✻✻

អរគុណព្រះម្ចាស់ អរព្រះគុណទាំងអស់គ្នា ព្រោះទ្រង់
ការពារយើងរាល់គ្នាឲ្យផុតទុក្ខ ឲ្យរស់ស្រណុកនៅក្នុងសុខ
សន្តិភាព ហើយផ្តល់កម្លាំងក្នុងជីវិតរស់នៅសព្វថ្ងៃ ។

✻✻✻✻✻✻✻✻✻✻

ពេលនេះឲ្យយើងច្រៀង ពេលនេះឲ្យយើងរាំ ពេលនេះ
ឲ្យយើងច្រៀងកោតសរសើរព្រះជាអម្ចាស់ កោតសរសើរ
ព្រះជាអម្ចាស់ យើងលើកតម្កើងព្រះនាមព្រះអង្គ
សូមឲ្យមនុស្ស គ្រប់ជាតិសាសន៍លើកតម្កើងព្រះជាម្ចាស់ ។

✻✻✻✻✻✻✻✻✻✻

បងប្អូនធ្វើអ្វីក៏ដោយ ចូរធ្វើទាំងអស់ ដើម្បីលើកតម្កើង
សិរីរុងរឿងរបស់ព្រះជាម្ចាស់ ។

✻✻✻✻✻✻✻✻✻✻

-បពិត្រព្រះបិតា!
ព្រះអង្គប្រមែប្រមូលកូនទាំងអស់
ឲ្យទទួលទានអាហាររួមគ្នា ។
-សូមប្រោសឲ្យកូនរួបរួមគ្នាដោយចិត្តស្រឡាញ់
សូមបង្ហាត់ឲ្យកូនចេះចែកអាហារដល់គ្នាទៅវិញទៅមកផង ។

**********

-កូនមានអំណរសប្បាយ ដោយបានរួមតុអាហារជាមួយគ្នា
សូមឲ្យថ្ងៃណាមួយ កូនបានរួមតុជាមួយគ្នា
ក្នុងព្រះរាជ្យរបស់ព្រះអង្គ ។
-យើងសូមអង្វរដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត
និងជាព្រះអម្ចាស់យើង ។ អាម៉ែន ។

**********

-ពេលនេះ យើងរួមគ្នាអរព្រះគុណព្រះជាអម្ចាស់
ព្រះអង្គសូមឲ្យយើងរួមគ្នា ឲ្យយើងស្រឡាញ់បងប្អូនទាំងអស់
ឲ្យយើងរួមគ្នាអរព្រះគុណព្រះអង្គ ។

**********

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 23



-បពិត្រព្រះបិតា
យើងខ្ញុំសូមអរព្រះគុណចំពោះអាហារ ពេលនេះ ។
សូមព្រះអង្គប្រោសប្រទានអាហារដល់អ្នកក្រីក្រទាំងឡាយ
ហើយក៏សូមប្រមូលយើងខ្ញុំឲ្យរួមគ្នា
ក្នុងព្រះរាជ្យរបស់ព្រះអង្គដែរ ។
-យើងខ្ញុំសូមអង្វរព្រះអង្គរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត
និងជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។

**********

-បពិត្រព្រះបិតា ព្រះអង្គស្រឡាញ់ជីវិត
ព្រះអង្គចិញ្ចឹម អស់បក្សាបក្សីនៅលើមេឃ
និងប្រទានឲ្យត្របកផ្កាមានសម្រស់ល្អ និងក្លិនក្រអូបដែរ ។
-សូមកោតសរសើរព្រះអម្ចាស់ ចំពោះអាហារដែលយើង
ហៀបនឹងទទួលទាន ។ សូមទ្រង់ព្រះមេត្តាប្រទាន ឲ្យមនុស្ស
លោកបានអាហារបរិភោគគ្រប់គ្រាន់ ជារៀងរាល់ថ្ងៃផង ។
-យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
ជាព្រះអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។

**********

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 24

# ៥ ខ្ញុំសូមអរព្រះគុណព្រះបិតា





## អធិដ្ឋានរួមជាមួយព្រះនាងម៉ារី

*- ខ្ញុំមានចិត្តត្រេកអរយ៉ាងខ្លាំង*
*ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ ។*

- ព្រះអង្គទតមើលមកខ្ញុំជាអ្នកបម្រើដ៏ទន់ទាបរបស់ព្រះអង្គ
អំណើះតទៅមនុស្សគ្រប់ជំនាន់នឹងពោលថា
ខ្ញុំជាអ្នកមានសុភមង្គលពិតមែន ។

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 25



- *ព្រះដ៏មានឫទ្ធានុភាពបានសម្តែងការដ៏ប្រសើរអស្ចារ្យ
ចំពោះរូបខ្ញុំ ។*

- ព្រះនាមរបស់ព្រះអង្គពិតជាវិសុទ្ធមែន!
ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដល់អស់អ្នក
ដែលកោតខ្លាចព្រះអង្គ នៅគ្រប់ជំនាន់តរៀងទៅ ។

  - *ទ្រង់បានសម្តែងឫទ្ធិបារមី
កម្ចាត់មនុស្សដែលមានចិត្តឆ្មើងឆ្មៃ
ទ្រង់បានទម្លាក់អ្នកកាន់អំណាចចុះពីតំណែង
ហើយទ្រង់លើកតម្កើងមនុស្សទន់ទាបឡើង ។*

- ទ្រង់បានប្រទានសម្បត្តិយ៉ាងបរិបូណ៌
ដល់អស់អ្នកដែលស្រេកឃ្លាន
ហើយបណ្តេញពួកអ្នកមានឲ្យត្រឡប់ទៅវិញដោយដៃទទេ ។

  - *ព្រះអង្គបានជួយប្រជារាស្ត្រអ៊ីស្រាអែល
ជាអ្នកបម្រើរបស់ព្រះអង្គ
ហើយតែងតែសម្តែងព្រះហឫទ័យមេត្តាករុណាដល់
លោកអប្រាហាំ និងពូជពង្សរបស់លោកជានិច្ចតរៀងទៅ
ដូចទ្រង់បានសន្យាជាមួយបុព្វបុរសរបស់យើង
ឥតភ្លេចសោះឡើយ ។*

៥

**កូនស្រឡាញ់ព្រះបិតា!**

- បពិត្រព្រះបិតាជាអម្ចាស់!
  កូនស្រឡាញ់ព្រះអង្គហើយ
  កូនមានបំណងស្រឡាញ់ព្រះអង្គតែមួយគត់
  អស់មួយជីវិត ។

- *ឱ! ព្រះអម្ចាស់អើយ!*
  *កូនស្រឡាញ់ព្រះអង្គណាស់*
  *ហើយកូនសូមព្រះអំណោយទានតែមួយគត់ពីព្រះអង្គ*
  *គឺ សូមឲ្យកូនស្រឡាញ់ព្រះអង្គរហូតអស់កល្បជានិច្ចផង ។*

- បពិត្រព្រះបិតា!
  ទោះបីជាកូនមិនអាចអះអាងថា
  កូនស្រឡាញ់ព្រះអង្គគ្រប់ពេលយ៉ាងណាក៏ដោយ
  ក៏ក្នុងចិត្តកូន តែងនឹកចង់ស្រឡាញ់ព្រះអង្គ
  គ្រប់ដង្ហើមចេញចូលដែរ ។

- *បពិត្រព្រះបិតាអើយ!*
  *សូមព្រះអង្គប្រោសឲ្យកូនស្រឡាញ់ព្រះអង្គជានិច្ចផង*
  *ទោះបីនៅពេលកូនរងទុក្ខលំបាកក៏ដោយ ។*

Petit Priere (31May11):Layout 1 6/[illegible]/2011 11:07 AM Page 27





- ឱ! ព្រះសង្គ្រោះរបស់កូនអើយ!
កូនស្រឡាញ់ព្រះអង្គ
ដ្បិតព្រះអង្គរងទុក្ខលំបាក
លើឈើឆ្កាងដោយសារតែកូន ។
កូនស្រឡាញ់ព្រះអង្គណាស់
ដ្បិតព្រះអង្គនាំកូនមកទីនេះ
ឲ្យរងទុក្ខលំបាក
រួមជាមួយព្រះអង្គដែរ ។



*សន្ត: យ៉ូហាន ម៉ារីវីយ៉ាណេ*

៥

## សូមកោតសរសើរព្រះអម្ចាស់

- បពិត្រព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត
ព្រះអង្គមានឫទ្ធានុភាពសព្វប្រការ ជាព្រះអម្ចាស់
មានព្រះហឫទ័យមេត្តាករុណាដ៏លើសលុប!

*- កូនសូមលើកតម្កើងព្រះអង្គ*
*សូមកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គ*
*សូមលើកតម្កើងព្រះអង្គរួមជាមួយសត្វលោកទាំងឡាយ*
*ដែលព្រះអង្គប្រតិស្ឋានមក ។*

- កូនសូមលើកតម្កើងព្រះអម្ចាស់
ដែលប្រទានបងប្រុសសុរិយាដ៏ល្អប្រសើរ ឲ្យ
បញ្ចេញរស្មីភ្លឺថ្លាចិញ្ចាចចិញ្ចែងរុងរឿងខ្លាំងណាស់ ។

*- សូមលើកតម្កើងព្រះអម្ចាស់ ដែលប្រទានបងស្រីចន្ទ្រា*
*និងតារាទាំងឡាយឲ្យភ្លឺនៅពេលយប់ ។*

- សូមលើកតម្កើងព្រះអម្ចាស់ ដែលប្រទានបងប្រុស
វាយោ និងពពកដ៏ត្រជាក់ត្រជុំ ។

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 29





- សូមលើកតម្កើងព្រះអម្ចាស់ ដែលប្រទានបងស្រីគង្គា ដែលមានប្រយោជន៍ និងមានតម្លៃដ៏ពិសេស ។
- សូមលើកតម្កើងព្រះអម្ចាស់ ដែលប្រទានបងប្រុសអគ្គី ឲ្យមកបំភ្លឺភាពងងឹតអន្ធិកា ។
- សូមលើកតម្កើងព្រះអម្ចាស់ ដែលប្រទានឲ្យបងប្អូន អត់ទោសដល់គ្នា ព្រោះ ខ្លួនស្រឡាញ់ព្រះអង្គ ។
- សូមលើកតម្កើងព្រះអម្ចាស់ ដែលប្រទានបងស្រីមច្ចុរាជ ។
- សូមសត្វលោកទាំងឡាយ លើកតម្កើងព្រះអម្ចាស់ សូមដាក់ខ្លួនបម្រើព្រះអង្គដោយចិត្តស្មោះ ។



សន្តៈ ហ្វ្រង់ស្វ័រ នៅអាស្សីស

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 30





# កូនសូមលះបង់ខ្លួន ថ្វាយព្រះអង្គ



-ឱ! ព្រះបិតាអើយ!
កូនសូមលះបង់ខ្លួន
ថ្វាយព្រះអង្គ
កូនក៏សូមផ្ញើជីវិត
ទាំងស្រុង
លើព្រះអង្គដែរ ។

- ឱ! ព្រះបិតាអើយ!
សូមព្រះអង្គប្រព្រឹត្តចំពោះកូនតាមព្រះហឫទ័យព្រះអង្គ
ព្រះអង្គប្រព្រឹត្តអ្វីក៏បាន
កូនសូមអរព្រះគុណព្រះអង្គជានិច្ច ។

Petit Priere (31May11):Layout 1 6/?/2011 11:07 AM Page 31





*- កូនសូមអរព្រះគុណព្រះអង្គចំពោះអ្វីៗទាំងអស់
កូនក៏សូមត្រៀមខ្លួននឹងធ្វើអ្វីៗគ្រប់យ៉ាងដែរ ។
កូនក៏យល់ព្រមនឹងអ្វីៗទាំងអស់ជានិច្ច
ឲ្យតែព្រះអង្គសម្រេចព្រះហឫទ័យនៅក្នុងខ្លួនកូន ។
កូនមិនចង់បានអ្វីក្រៅពីគាប់ព្រះហឫទ័យរបស់ព្រះអង្គទេ
កូនសូមប្រគល់ខ្លួនទាំងស្រុងនៅក្នុងព្រះហស្តព្រះអង្គ ។*

- ព្រោះកូនស្រឡាញ់ព្រះអង្គ
កូនសូមថ្វាយខ្លួនដោយស្មោះអស់ពីដួងចិត្ត
ព្រោះតែសេចក្ដីស្រឡាញ់នោះ
កូនត្រូវតែប្រគល់ខ្លួនទាំងស្រុងលើព្រះអង្គ
និងផ្ញើជីវិតកូននៅក្នុងព្រះហស្តព្រះអង្គ
ដោយគ្មានលក្ខ័ណ ។

*- កូនសូមប្រគល់ខ្លួនកូនទៅក្នុងព្រះហស្តព្រះអង្គ
ដោយជឿទុកចិត្តទាំងស្រុងលើព្រះអង្គ
ព្រោះព្រះអង្គជាព្រះបិតារបស់កូន ។*

*តាមលោកសាលឌឺហ្វូកូ*

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 32

# ៦ សូមកោតសរសើរព្រះយេស៊ូ

៦



## ព្រះគ្រីស្តបន្ទាបព្រះកាយ និងទទួលសិរីរុងរឿង

- ទោះបីព្រះគ្រីស្តមានឋានៈជាព្រះជាម្ចាស់ក៏ដោយ ក៏ព្រះអង្គពុំបានក្តោបក្តាប់ឋានៈដែលស្មើនឹងព្រះជាម្ចាស់នេះ ទុកជាកម្មសិទ្ធិផ្ដាច់មុខរបស់ព្រះអង្គឡើយ ។ ផ្ទុយទៅវិញ ព្រះអង្គបានលះបង់អ្វីៗទាំងអស់មកយកឋានៈជាអ្នកបម្រើ ។

  - *ព្រះអង្គបានទៅជាមនុស្សដូចមនុស្សឯទៀតៗ ហើយក៏រស់នៅក្នុងភាពជាមនុស្សសាមញ្ញដែរ ។ ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គត គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង ។*

- ហេតុនេះហើយ បានជាព្រះជាម្ចាស់លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រោសប្រទានឲ្យព្រះអង្គមានព្រះនាមប្រសើរលើសអ្វីៗទាំងអស់ ដើម្បីឲ្យអ្វីៗទាំងអស់ ទាំងនៅលើមេឃ ទាំងនៅលើផែនដី ទាំងនៅក្រោមដី នាំគ្នាក្រាបថ្វាយបង្គំ នៅពេលឮព្រះនាមព្រះយេស៊ូ និងឲ្យមនុស្សគ្រប់ភាសាប្រកាសឡើងថា ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់
ដើម្បីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ជាព្រះបិតា ។

*តាមភីលីព ២*

៦

## សូមកោតសរសើរព្រះយេស៊ូគ្រីស្ត

*ឱ ព្រះយេស៊ូអើយ !*
*ព្រះអង្គជាតំណាងរបស់ព្រះបិតាដែលយើងមើលពុំឃើញ*
*ព្រះអង្គជារៀមច្បងនៃអ្វីៗទាំងអស់*
*ដែលព្រះជាម្ចាស់បានបង្កើតមក*

៦

ដ្បិតព្រះជាម្ចាស់បានបង្កើតអ្វីៗសព្វសារពើក្នុង
អង្គព្រះគ្រីស្ត ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី
ទាំងអ្វីៗដែលមើលឃើញ ទាំងអ្វីៗដែលមើលមិនឃើញ
ទាំងទេវរាជ្យ ទាំងអ្វីៗដែលមានបារមីគ្រប់គ្រង
ទាំងវត្ថុសក្តិសិទ្ធិ និងអំណាចនានា
ព្រះជាម្ចាស់បានបង្កើតទាំងអស់មក
ដោយសារព្រះគ្រីស្ត និងសម្រាប់ព្រះគ្រីស្ត ។

*ឱ ព្រះយេស៊ូអើយ !*
*ព្រះអង្គមានព្រះជន្មមុនអ្វីៗទាំងអស់*
*ហើយអ្វីៗទាំងអស់ក៏ស្ថិតនៅរួមគ្នាដោយសារព្រះអង្គដែរ ។*
*ព្រះអង្គជាសិរសានៃព្រះសហគមន៍*
*ដែលជាព្រះកាយរបស់ព្រះអង្គ ។*

Petit Priere (31May11):Layout 1  6/2/2011  11:07 AM  Page 35







ឱ ព្រះយេស៊ូគ្រីស្តអើយ!
ព្រះអង្គជាដើមកំណើត
នៃអ្វីៗទាំងអស់
ក្នុងចំណោមមនុស្សស្លាប់ ។
ព្រះអង្គមានព្រះជន្មមុនគេ
ដើម្បីធ្វើជាប្រមុខក្នុងគ្រប់វិស័យ
ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យ
ឲ្យគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ ស្ថិតក្នុងព្រះគ្រីស្ត ។

*ព្រះជាម្ចាស់បានសម្រុះសម្រួលអ្វីៗទាំងអស់នៅលើផែនដី*
*និងនៅស្ថានបរមសុខ ឲ្យជានានឹងព្រះអង្គវិញ*
*ដោយសារព្រះគ្រីស្ត និងសម្រាប់ព្រះគ្រីស្ត ។*
*ព្រះជាម្ចាស់បានធ្វើឲ្យមានសន្តិភាព*
*ដោយព្រះបុត្រាបង្ហូរព្រះលោហិតនៅលើឈើឆ្កាង ។*

*តាមកូឡុស ១*

## ចូរនឹកដល់ព្រះយេស៊ូគ្រីស្ត

*- ចូរនឹកដល់ព្រះយេស៊ូគ្រីស្ត*
*ដែលមានព្រះជន្មរស់ឡើងវិញ*
*ព្រះអង្គជាប់ព្រះញាតិវង្សព្រះបាទដាវីឌ ។*

៦ - ពាក្យនេះគួរឲ្យជឿថា
ប្រសិនបើយើងស្លាប់ជាមួយព្រះអង្គ
យើងក៏មានជីវិតរស់រួមជាមួយព្រះអង្គដែរ ។

*- ប្រសិនបើយើងស៊ូទ្រាំ*
*យើងនឹងបានគ្រងរាជ្យជាមួយ ព្រះអង្គ ។*

- ប្រសិនបើយើងបដិសេធមិនទទួលស្គាល់ព្រះអង្គ
ព្រះអង្គក៏នឹងបដិសេធមិនទទួលស្គាល់យើងវិញដែរ ។

*- ប្រសិនបើយើងមិនស្មោះត្រង់*
*ព្រះអង្គនៅតែស្មោះត្រង់ដដែល*
*ដ្បិតព្រះអង្គមិនអាចបដិសេធព្រះអង្គផ្ទាល់បានឡើយ ។*

*២ ធម ២*

Petit Priere (31May11):Layout 1 6/2/2011 11:07 AM Page 37



## ព្រះយេស៊ូសូមកុំភ្លេចខ្ញុំ

បន្ទរ៖ *ព្រះយេស៊ូ សូមកុំភ្លេចខ្ញុំ*
*ពេលព្រះអង្គយាងមកគ្រងរាជ្យ ។*

ព្រះយេស៊ូមិនដែលបោះបង់
អស់អ្នកដែលកើតទុក្ខឡើយ (បន្ទរ)

*ព្រះយេស៊ូស្ដាប់បង្គាប់ព្រះបិតា*
*រហូតសោយទិវង្គត* *(បន្ទរ)*

ព្រះយេស៊ូត្រូវគេបាក់ទម្លុះឱ្យរ៉ា
និងព្រះហស្ដរបស់ព្រះអង្គ (បន្ទរ)

*ព្រះយេស៊ូជាព្រះបុត្រា និង*
*ជាសិរីរុងរឿងនៃព្រះបិតា* *(បន្ទរ)*

## ចូរនឹកដល់ព្រះយេស៊ូគ្រីស្ត

*បន្ទរ ក្រោយឃ្លានីមួយៗ៖ *សូមអាណិតអាសូរយើងខ្ញុំ*
ឬ *យើងខ្ញុំកោតសរសើរព្រះយេស៊ូ ។*

៦

-ព្រះយេស៊ូគ្រីស្ត ជាសិរីរុងរឿងនៃព្រះបិតា
-ព្រះយេស៊ូគ្រីស្ត ជាពន្លឺបំភ្លឺជីវិតយើងខ្ញុំ
-ព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះនាងព្រហ្មចារិនីម៉ារី

- *ព្រះយេស៊ូគ្រីស្ត មានឫទ្ធានុភាពដ៏មហិមា*
- *ព្រះយេស៊ូគ្រីស្ត មានព្រះហឫទ័យអត់ធ្មត់ក្រៃលែង*
- *ព្រះយេស៊ូគ្រីស្ត ស្រឡាញ់អ្នកកាន់ព្រហ្មចារីធម៌*

-ព្រះយេស៊ូគ្រីស្ត ស្រឡាញ់យើងខ្ញុំ
-ព្រះយេស៊ូគ្រីស្ត ប្រទានសុខសន្តិភាព
-ព្រះយេស៊ូគ្រីស្ត ជាគំរូនៃអំពើល្អទាំងឡាយ

*- ព្រះយេស៊ូគ្រីស្ទ ស្រឡាញ់មនុស្សទាំងអស់*
*- ព្រះយេស៊ូគ្រីស្ទ ជាព្រះអម្ចាស់យើងខ្ញុំ*
*- ព្រះយេស៊ូគ្រីស្ទ ជាទីពឹងពាក់យើងខ្ញុំ*

- ព្រះយេស៊ូគ្រីស្ទប្រោសប្រណីអស់អ្នកកម្សត់ទុគ៌តទាំងឡាយ
- ព្រះយេស៊ូគ្រីស្ទ មានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែង
- ព្រះយេស៊ូគ្រីស្ទ ជាមាគ៌ា និងជាអាយុជីវិតយើងខ្ញុំ



*- ព្រះយេស៊ូគ្រីស្ទ ជាព្រះអម្ចាស់នៃបុព្វបុរសទាំងឡាយ*
*- ព្រះយេស៊ូគ្រីស្ទ ប្រទានឲ្យចិត្តមនុស្សបានបរិសុទ្ធ*
*- ព្រះយេស៊ូគ្រីស្ទ ជាអំណរសប្បាយនៃមរណបុគ្គល*

- ព្រះយេស៊ូគ្រីស្ទ មេត្តាករុណា អាណិតអាសូរយើងខ្ញុំ
- ព្រះយេស៊ូគ្រីស្ទ ជាកម្លាំងរបស់យើង
- ព្រះយេស៊ូគ្រីស្ទ ជាគង្វាលដ៏សប្បុរសនៃមនុស្សទាំងឡាយ ។

***********

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 40

# ៧ លើកតម្កើងអគ្គសញ្ញាដ៏វិសុទ្ធ

៧



## គោរពព្រះកាយ ព្រះលោហិតព្រះគ្រីស្ត

- *កូនសូមកោតសរសើរព្រះបិតាចំពោះអគ្គសញ្ញាដ៏វិសុទ្ធ*
  *ដែលជាច្បាប់តាំងពីដើមរៀងរហូតមក*
  *កូនសូមគោរពដោយបន្ទាបចិត្តកាយចំពោះក្បួនពិធី*
  *ដែលពង្រឹងជំនឿកូនឲ្យកាន់តែរឹងមាំថែមទៀត ។*

- សូមលើកតម្កើងសិរីរុងរឿង
  របស់ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ
  និងសូមប្រកាសសិរីរុងរឿងរបស់ព្រះអង្គ ។

## សូមលើកតម្កើងអគ្គសញ្ញាដ៏វិសុទ្ធ

- *ចូរយើងគ្រប់គ្នាឱនកាយក្រាបថ្វាយបង្គំ អគ្គសញ្ញាពិសិដ្ឋថ្លៃថ្លាឧត្តម គឺព្រះកាយានៃព្រះយេស៊ូ ទ្រង់ចងសម្ព័ន្ធមេត្រីថ្មី ទោះបីជាភ្នែកយើងមើលមិនឃើញ តែយើងជឿថា ទ្រង់គង់នៅទីនេះ ។*

- ចូរយើងថ្លែងឡើងសរសើរតម្កើងព្រះម្ចាស់ គឺព្រះបិតា និងព្រះបុត្រាវិសេស ទាំងព្រះវិញ្ញាណជាព្រះតែឯក ទ្រង់មានសិរីរុងរឿងថ្លាថ្លៃ តេជានុភាពពេញទាំងមេឃដី វិសុទ្ធអស់កាលជាអង្វែងតរៀងទៅ ។

៧

សូមលើកតម្កើងអគ្គសញ្ញាដ៏វិសុទ្ធ ជាភាសាឡាតាំង

*Tantum ergo sacraméntum venerémur cérnui,*
*et antiquum documéntum novo cedat ritui,*
*praestet fides suppleméntum sénsuum deféctui.*
*Genitóri Genitóque laus et iubilátio,*
*salus, honor, virtus quoque sit et benedictio,*
*procedénti ab utróque comper sit laudátio. Amen.*

## សូមគោរពអគ្គសញ្ញាដ៏វិសុទ្ធ

- បពិត្រព្រះបិតា! ដោយអគ្គសញ្ញាអរព្រះគុណ
  ព្រះអង្គបានប្រោសកូនទាំងឡាយ
  ឲ្យចូលរួមជាមួយព្រះបុត្រាដែលបានបូជាព្រះជន្ម
  និងទទួលព្រះជន្មថ្មីដ៏រុងរឿង ។
- សូមទ្រង់ព្រះមេត្តាប្រោសប្រទានឲ្យគ្រីស្តបរិស័ទទាំងឡាយ
  រួមជាព្រះកាយតែមួយដែលជាព្រះសហគមន៍
  ដើម្បីធ្វើជាសញ្ញាសម្គាល់បញ្ជាក់ថា
  ព្រះអង្គស្រឡាញ់មនុស្សលោក ។

៧

## យើងលើកតម្កើងព្រះបិតា

បពិត្រព្រះបិតាដ៏វិសុទ្ធ នៅពិធីជុបលៀងចុងក្រោយបំផុត
ព្រះយេស៊ូបានបូជាព្រះជន្មថ្វាយព្រះអង្គ
ទុកជាកូនចៀមដ៏ឥតសៅហ្មង ។
ពេលយើងខ្ញុំចូលរួមក្នុងសក្ការបូជានេះ
ព្រះអង្គប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គឲ្យយើងខ្ញុំ
ជាសញ្ញាសម្គាល់បញ្ជាក់ថា
មនុស្សគ្រប់រូបអាចចូលរួមក្នុងមហាគ្រួសារតែមួយ ។

## សូមលើកតម្កើងព្រះជាម្ចាស់

បពិត្រព្រះយេស៊ូជាអម្ចាស់! គេឆ្កាងព្រះអង្គ ។
តាមស្នាមរបួសមានទឹក និងព្រះលោហិតហូរមក ។
សូមព្រះអង្គព្រះសណ្ដាប់ ពាក្យអង្វររបស់ព្រះសហគមន៍
ជាព្រះមហេសីរបស់ព្រះអង្គ ។

*បន្ទរ៖ សូមអាណិតអាសូរយើងខ្ញុំ ។*

ព្រះយេស៊ូ ដែលស្ដាប់បង្គាប់ព្រះបិតារហូតដល់សោយទិវង្គត
គេយកលំពែងចាក់ទម្លុះព្រះឱរ៉ា
ហើយរំព្រះសពក្នុងសំពត់ស្នប (បន្ទរ)

ព្រះយេស៊ូ ជាផ្លូវរបស់អស់អ្នកវង្វេង
ព្រះអង្គប្រទានព្រះជន្មព្រះបិតាឲ្យយើង (បន្ទរ)

ព្រះយេស៊ូ ជាសេចក្ដីសុខសាន្ត និងជាស្ពានមេត្រីរបស់យើង
ព្រះអង្គដោះបន្ទុកពីអ្នកបាប (បន្ទរ)

ព្រះយេស៊ូ ជាមិត្រសម្លាញ់របស់មនុស្សទាំងអស់
ព្រះអង្គជាបងប្រុសរបស់អ្នកក្រីក្រ (បន្ទរ)

ព្រះយេស៊ូ ជាព្រះវិហារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់
ព្រះអង្គជាទ្វារនៃស្ថានបរមសុខ (បន្ទរ)

៧

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 44



## ព្រះអម្ចាស់យេស៊ូ ផ្ដល់ជីវិតឱ្យយើង

បន្ទរ៖ *សូមលើកតម្កើងព្រះកាយនិងព្រះលោហិត ។*

ព្រះគ្រីស្ត សូមឲ្យយើងអរព្រះគុណនិងនឹករឭកដល់ព្រះអង្គ ។
- *សូមប្រោសឲ្យយើងខ្ញុំរក្សាជំនឿ និងចូលរួមក្នុងពិធីដ៏អស្ចារ្យរបស់ព្រះអង្គផង ។ (បន្ទរ)*

ព្រះគ្រីស្ត ជាមហាបូជាចារ្យ រួមជាមួយព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត ។

៧

- *សូមប្រោសឲ្យអ្នកបម្រើពិធីបុណ្យ បានគាប់ព្រះហឫទ័យព្រះអង្គផង ។ (បន្ទរ)*

ព្រះគ្រីស្ត ប្រោសឲ្យអស់អ្នកចូលរួមថ្វាយអភិបូជា ចូលក្នុងព្រះកាយតែមួយរបស់ព្រះអង្គ ។
- *សូមឲ្យយើងខ្ញុំរួមគ្នាជាធ្លុងតែមួយផង ។ (បន្ទរ)*

ព្រះគ្រីស្តជាអាហារមកពីព្រះបិតាប្រោសឲ្យយើងជាសះស្បើយ ។
- *សូមឲ្យយើងខ្ញុំបានសេចក្ដីសុខសាន្ត ខាងរូបកាយ និងព្រលឹងផង ។ (បន្ទរ)*

ព្រះគ្រីស្ត សូមឲ្យយើងទទួលព្រះកាយនិងប្រកាសអំពីព្រះអង្គ ដែលសោយទិវង្គតនិងទទួលព្រះជន្មថ្មីដ៏រុងរឿង ។
- *សូមឲ្យយើងខ្ញុំទទួលជីវិតអស់កល្បជានិច្ចផង ។(បន្ទរ)*

## សូមកោតសរសើរ

សូមកោតសរសើរព្រះបិតាជាព្រះជាម្ចាស់!
សូមកោតសរសើរព្រះនាមព្រះអង្គ!
សូមកោតសរសើរព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ដ៏ពិតប្រាកដ
និងជាមនុស្សដ៏ពិតប្រាកដដែរ!
សូមកោតសរសើរព្រះនាមព្រះយេស៊ូ!
សូមកោតសរសើរព្រះហឫទ័យដ៏វិសុទ្ធរបស់ព្រះអង្គ!
សូមកោតសរសើរព្រះលោហិតដ៏វិសុទ្ធរបស់ព្រះអង្គ!
សូមកោតសរសើរព្រះយេស៊ូដែលគង់នៅជាមួយយើង
តាមអគ្គសញ្ញាដ៏វិសុទ្ធ!
សូមកោតសរសើរព្រះវិញ្ញាណដ៏វិសុទ្ធដែលលួងលោម!
សូមកោតសរសើរសន្តីព្រហ្មចារីម៉ារីជាព្រះមាតាព្រះយេស៊ូ!
សូមកោតសរសើរសន្តីដ៏និមលគ្មានជំពាក់បាបកម្ម!
សូមកោតសរសើរសន្តីយាងឡើងស្ថានបរមសុខទទួលសិរីរុងរឿង!
សូមកោតសរសើរសន្ត:យ៉ូសែបជាស្វាមីព្រះនាងម៉ារី!
សូមកោតសរសើរព្រះជាម្ចាស់ ដែលប្រទានឲ្យមានទេវទូត
និងសន្តបុគ្គលទាំងឡាយ ។

៧

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 46



# ៨ កូនសូមអង្វរព្រះវិញ្ញាណ



## សូមយាងមក ឱ! ព្រះវិញ្ញាណ

សូមយាងមក ឱ! ព្រះវិញ្ញាណ ឲ្យយើងពោរពេញ
ដោយភ្លើងនៃក្តីស្រឡាញ់! សូមយាងមក ឱ! ព្រះវិញ្ញាណៗ ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 47



## ភ្លើងនៃក្ដីស្រឡាញ់

ភ្លើង! ភ្លើង! ភ្លើង!
នៃក្ដីស្រឡាញ់មកសណ្ឋិតលើពួកយើង
ឲ្យពួកយើងពោរពេញទៅដោយ ព្រះវិញ្ញាណដ៏វិសុទ្ធ ។

*បន្ទរ៖ ឱ! ព្រះយេស៊ូគ្រីស្ដអើយ! ប្រទានភ្លើងឲ្យយើងខ្ញុំ*
*ឱ! ព្រះយេស៊ូគ្រីស្ដអើយ! ប្រទានភ្លើងក្នុងចិត្តយើងខ្ញុំ ។*



## សូមអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ

សូមថ្វាយបង្គំព្រះបិតា
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ! អាម៉ែន ។

- បពិត្រព្រះបិតា !
  សូមប្រោសប្រទានព្រះវិញ្ញាណមកបំភ្លឺយើងខ្ញុំ
  ឲ្យប្រព្រឹត្តតែកិច្ចការដែលគាប់ព្រះហឫទ័យព្រះអង្គ
  និងឲ្យយើងខ្ញុំមានអំណរតរៀងទៅ
  ដោយរួមជាមួយព្រះយេស៊ូគ្រីស្ដជាអម្ចាស់យើងខ្ញុំ ។
  អាម៉ែន ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 48



# សូមអង្វរព្រះវិញ្ញាណ

*បទពាក្យ ៧*

១- ឱ! ព្រះវិញ្ញាណព្រះបវរ សូមយាងកុះករក្នុងដួងចិត្ត
សូមបាត់ពន្លឺរស្មីពិត ឲ្យមកតាំងស្ថិតលើអស់យើង ។

២- ឱ! ព្រះបិតាអ្នកកម្សត់ ក្រីក្រទុគ៌តបិតាថ្កើង
យាងមកប្រទានកុំបីឆ្មើង អំណោយក្រាស់ស្ដើងកូនទទួល ។

៣- សូមយាងមកបំភ្លឺគំនិត បំភ្លឺដួងចិត្តកុំឲ្យជ្រួល
ទប់ឲ្យនឹងនមិនរំជួល រស់នៅសុខស្រួលក្នុងអំណោយ ។

៤- ព្រះអង្គលួងលោមដួងចិត្តខ្ញុំ ទ្រង់គង់សំងំមិនមែនខ្សោយ
ព្រះអង្គជាម្លប់ពីមុខក្រោយ ត្រជាក់ត្រជុំពេលខ្ញុំហត់ ។

៥- ព្រះអង្គប្រទានឲ្យសម្រាក កុំឲ្យលំបាកហួសកំណត់
ក្ដៅហួតក្ដៅហែងហេវកម្សត់ ព្រះអង្គជាផ្លិតបក់ត្រជាក់ ។

៦- កាលណាយើងខ្ញុំកើតទុក្ខព្រួយ ព្រះអង្គលើកស្ទួយមិនស្ទើរស្ទាក់
ទឹកចិត្តខ្ញុំឡើងខ្ពស់ប្រត្យ័ក្ស ឥតបីមានញាក់ស្លុតរន្ធត់ ។

៧- ឱ! ពន្លឺភ្លឺថ្លែងត្រចះ ត្រចង់ឥតខ្ចះមិនរលត់
យាងមកបំភ្លឺនិងបំពត់ អ្នកជឿសង្ឃឹមលើព្រះអង្គ ។

៨- កុំតែព្រះអង្គយាងមកប្រោស    យាងមកសន្ដោសគ្មានបង្អង់
កុំអីមនុស្សលោកគ្មានផ្លូវត្រង់    គ្មានចិត្តគ្មានចង់ធ្វើអ្វីឡើយ ។

៩- កិច្ចការទាំងអស់ដែលគេធ្វើ    ជំពាក់បាបស្មើរពុំដែលស្បើយ
សូមទ្រង់យាងមកលាងឲ្យហើយ    អ្វីៗក្រខ្វក់ចេញឲ្យអស់ ។

១០.សូមទ្រង់ស្រោចលើចិត្តហែងហួត    កុំឲ្យក្រៀមស្ងួតសោះកក្រោះ
និងចិត្តដែលមានស្នាមរបួស    ឲ្យមានសម្រស់ស្រស់បំព្រង ។

១១.សូមបន្ទន់ចិត្តកាយវាចា    កុំឲ្យឫស្យាមានសៅហ្មង
សូមប្រទានតាមព្រះបំណង    ហឫទ័យថ្លាយង់កុំខានណា ។

១២.សូមតម្រង់ចិត្តកោងវេវវៀច    ចិត្តខូចកាចកៀចដោយហិង្សា
ខន្តីអំណត់តាមមាគ៌ា    តាមចិត្តប្រាថ្នាហឫទ័យត្រង់ ។

១៣.សូមទ្រង់ប្រទានអំណោយសព្វ    ឲ្យមានភពភ័ព្វបែបទំនង
ដល់អ្នកជឿផងតាមបំណង    ចិត្តជឿលើទ្រង់ជាអម្ចាស់ ។

១៤.សូមទ្រង់ប្រទានបុណ្យកុសល    ឲ្យបានមគ្គផលក្រៃលក្រៃក្រាស់
អំណរសប្បាយមានដេរដាស    រហូតដល់អស់កល្បទៅហោង ។

៨

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 50

# ៩ កូនទឹករញក និង អរព្រះគុណនាងម៉ារី



Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 51



- *បពិត្រព្រះនាងម៉ារី !*
*កូននឹករឭក និងសូមអរគុណព្រះនាង*
*កូនសូមអរគុណព្រះនាងដែលបានបង្កើតនិងចិញ្ចឹមព្រះយេស៊ូ*
*គឺព្រះអង្គដែលសោយទិវង្គតដើម្បីយើងទាំងអស់គ្នា ។*

  - កូននឹករឭកព្រះនាងម៉ារី កូនសូមកោតសរសើរព្រះនាង
  កូនសូមកោតសរសើរ ដោយព្រះនាងមានជំនឿរឹងមាំ
  ដោយព្រះនាងអធិដ្ឋានយ៉ាងស្ងៀមស្ងាត់
  ដោយព្រះនាងរស់នៅតាមព្រះបន្ទូលព្រះអម្ចាស់ ។

- *បពិត្រព្រះនាងម៉ារី កូននឹករឭកដល់ព្រះនាង*
*សូមព្រះនាងម៉ារី ជួយឲ្យកូនស្គាល់ព្រះយេស៊ូ*
*ឲ្យកូនស្តាប់ការត្រាស់ហៅរបស់ព្រះអង្គ*
*និងចេញទៅតាមព្រះហឫទ័យព្រះអង្គផង ។*

*អន់ជ្រេ សែវ*

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 52



## សូមពឹងផ្អែកលើព្រះនាងម៉ារី

ឱ! ព្រះនាងម៉ារី ជាព្រះមាតានៃព្រះគ្រីស្តជាអម្ចាស់អើយ
យើងខ្ញុំសូមចូលជ្រកកោនក្រោមម្លប់ព្រះបារមីព្រះនាង
សូមព្រះនាងកុំលះបង់ពាក្យអង្វរ
ដែលយើងខ្ញុំទូលព្រះនាងក្នុងគ្រាមានអាសន្នឡើយ
តែសូមព្រះនាងជួយរំដោះយើងខ្ញុំ
ឲ្យរួចពីអន្តរាយគ្រប់បែបយ៉ាងផង ។

*****



## សូមព្រះនាងម៉ារីទទួលយើងខ្ញុំ

ឱ! ព្រះនាងម៉ារី ជាព្រះមាតាព្រះគ្រីស្តជាអម្ចាស់
និងជាមាតាយើងខ្ញុំអើយ !
យើងខ្ញុំសូមគោរពលើកតម្កើងព្រះនាងដ៏ឧត្តមប្រសើរ
លើសអស់ទេវទូត និងសន្តបុគ្គលទាំងឡាយ ។
សូមព្រះនាងសព្វព្រះហឫទ័យទទួលយើងខ្ញុំជាកូនចៅព្រះនាង
ហើយសូមដឹកនាំយើងខ្ញុំឆ្ពោះទៅព្រះយេស៊ូជាព្រះបុត្រា
ព្រះនាង និងជាព្រះអម្ចាស់យើងខ្ញុំ
ដើម្បីឲ្យយើងខ្ញុំបានទទួលអំណរសប្បាយ ។

## ព្រះនាងព្រហ្មចារិនីម៉ារី

ឱ! ព្រះនាងព្រហ្មចារិនីម៉ារី ដ៏មានធម៌មេត្តាអើយ
តាំងពីដើមរៀងមកពុំដែលឮថា ព្រះនាងបានលះបង់បោល
អ្នកណាដែលចូលមកសូមព្រះនាងជួយការពារឡើយ ។
ឱ! ព្រះនាងម៉ារី ជាមាតាខ្ញុំអើយ ថ្វីបើខ្ញុំមានបាបច្រើន
ក៏ខ្ញុំមានចិត្តសង្ឃឹមយ៉ាងមាំមួន
ហើយចូលមកប្រណម្យទៀបបាទាព្រះនាងដែរ ។
ឱ! ព្រះមាតាព្រះយេស៊ូអើយ សូមកុំលះបង់ខ្ញុំឡើយ
តែសូមទ្រង់ព្រះមេត្តាសណ្តាប់ពាក្យអង្វររបស់ខ្ញុំ
ដោយព្រះហប្ញទ័យប្រោសប្រណីផង ។

## ទេវទូតជូនដំណឹងព្រះនាងម៉ារី

*ពេលព្រឹក ពេលថ្ងៃត្រង់ ពេលល្ងាច គ្រីស្តបរិស័ទតែងតែនឹកសញ្ជឹង អំពីព្រះគ្រីស្តកើតមកជាមនុស្ស ដោយរួមគំនិតជាមួយព្រះនាងម៉ារី ។*

* ព្រះជាម្ចាស់បានចាត់ទេវទូតមកជូនដំណឹងដល់នាងម៉ារី

**- នាងម៉ារីមានគភ៌ ដោយសារព្រះវិញ្ញាណ ។**

*- បពិត្រព្រះនាងម៉ារី ...*

* នាងខ្ញុំជាអ្នកបម្រើព្រះអម្ចាស់

**- សូមឲ្យបានសម្រេចតាមព្រះហឫទ័យព្រះអង្គ ។**

*- បពិត្រព្រះនាងម៉ារី ...*

* ព្រះបុត្រាបានកើតមកជាមនុស្ស

**- ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា ។**

*- បពិត្រព្រះនាងម៉ារី ...*

* សូមជួយអង្វរព្រះអង្គឲ្យយើងខ្ញុំផង

**- ដើម្បីឲ្យយើងខ្ញុំទទួលជីវិតថ្មី**
**តាមព្រះបន្ទូលសន្យារបស់ព្រះយេស៊ូគ្រីស្ត ។**

*- បពិត្រព្រះនាងម៉ារី ...*

Petit Priere (31May11):Layout 1 6/[illegible]/2011 11:08 AM Page 55



សូមតាំងចិត្តអធិដ្ឋាន៖

- ឱ! ព្រះជាម្ចាស់យើងខ្ញុំអើយ
  សូមព្រះអង្គប្រទានព្រះអំណោយទានដ៏ថ្លៃថ្លារបស់ព្រះអង្គ
  ឲ្យយើងខ្ញុំដែលទទួលដំណឹងពីទេវទូតមកថា
  ព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះអង្គ
  ទ្រង់យាងមកចាប់កំណើតជាមនុស្ស ។

  - *ដោយព្រះមហាករុណាទិគុណរបស់ព្រះយេស៊ូគ្រីស្ត*
    *ដែលទ្រង់បានសោយទុក្ខលំបាក*
    *និងសោយទិវង្គតឰដ៏ឈើឆ្កាង ។*

- សូមព្រះអង្គប្រទានឲ្យយើងខ្ញុំ
  បានសិរីរុងរឿងជាមួយព្រះយេស៊ូ
  ដែលមានព្រះជន្មថ្មីដ៏រុងរឿង
  និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ ។ អាម៉ែន ។

## សម្តេចក្សត្រីនៃស្ថានបរមសុខ

(សម្រាប់រដូវបុណ្យចម្លង)

* សូមកោតសរសើរសម្តេចក្សត្រីនៃស្ថានបរមសុខ
ទ្រង់អរសប្បាយឡើង *អាលេលូយ៉ា*

- **ដ្បិតព្រះយេស៊ូគ្រីស្តជាបុត្រារបស់ព្រះនាង** *អាលេលូយ៉ា ។*

* *ព្រះអង្គ* ទទួលព្រះជន្មថ្មីដ៏រុងរឿង *តាមព្រះបន្ទូលសន្យា*
*អាលេលូយ៉ា ។*

- ***សូមព្រះនាងជួយអង្វរព្រះជាអម្ចាស់ឲ្យយើងខ្ញុំផង***
*អាលេលូយ៉ា ។*

៩

* ឱ! ព្រះនាងម៉ារី សូមសប្បាយរីករាយឡើង *អាលេលូយ៉ា*

- **ដ្បិតព្រះបុត្រាព្រះនាងទទួលព្រះជន្មថ្មីដ៏រុងរឿង**
*អាលេលូយ៉ា ។*

សម្តេចក្សត្រីនៃស្ថានបរមសុខ

*Regína cœli lætáre, allelúia,*
*quia quem meruísti portáre, allelúia,*
*ressurréxit sicut dixit, allelúia;*
*ora pro nobis Deum, allelúia.*

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 57



សូមតាំងចិត្តអធិដ្ឋាន៖

ឱ ព្រះបិតាអើយ!

ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សលោកទាំងអស់
បានអំណរសប្បាយ ដោយព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ
ដែលបានទទួលព្រះជន្មថ្មីដ៏រុងរឿង ។
តាមរយៈព្រះនាងព្រហ្មចារិនីម៉ារី ជាមាតាព្រះអង្គ
យើងខ្ញុំសូមទូលអង្វរព្រះអង្គ
សូមទ្រង់ប្រោសប្រទាន
ឲ្យយើងខ្ញុំបានអំណរសប្បាយនឹងមានជីវិតអស់កល្បជានិច្ច
រួមជាមួយព្រះយេស៊ូ ជាអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 58





## អធិដ្ឋានតាមមាលា

* ពិធីសូត្រផ្គាំ ឬមាលា មានគោលដៅណែនាំគ្រីស្តបរិស័ទ ឲ្យរួមចិត្តគំនិតជាមួយព្រះនាងម៉ារី ដែលជាគ្រីស្តបរិស័ទគំរូ ដើម្បីនឹកសញ្ជឹងអំពីព្រឹត្តិការណ៍សំខាន់ៗក្នុងការសង្គ្រោះ និងអធិដ្ឋានផង ។

*១. យើងចាប់ផ្តើម៖*

*"ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធ" ។*

*២. យើងអាន ឬសញ្ជឹងអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យមួយដែលព្រះជាម្ចាស់បានប្រព្រឹត្ត ដើម្បីសង្គ្រោះមនុស្សលោក ។*

*៣. បន្ទាប់មកសូត្រធម៌ "ឱ ព្រះបិតា" ១ ដង "បពិត្រព្រះនាងម៉ារី" ១០ ដង "សូមកោតសរសើរ" ១ ដង ។*

*៤. ពេលសូត្រធម៌ទាំងនេះរួច ត្រូវនឹកសញ្ជឹងតទៅព្រឹត្តិការណ៍មួយទៀត ។ ព្រឹត្តិការណ៍ទាំងអស់មាន ៤ ភាគ គឺ៖*

### I. ព្រឹត្តិការណ៍នាំឲ្យអរសប្បាយ

1- ព្រះជាម្ចាស់ចាត់ទេវទូតមកជូនដំណឹងដល់ព្រះនាងម៉ារី

2- ព្រះនាងម៉ារីទៅជម្រាបសួរនាងអេលីសាបិត

3- ព្រះយេស៊ូប្រសូតមកក្នុងលោកយើងនេះ

4- ព្រះនាងម៉ារីបីព្រះឱរសយេស៊ូទៅថ្វាយព្រះជាម្ចាស់

5- ព្រះនាងម៉ារីនិងលោកយ៉ូសែបរកឃើញព្រះកុមារយេស៊ូ ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 59



## II. ព្រឹត្តិការណ៍សម្ដែងព្រះពន្លឺ

1- ព្រះយេស៊ូទទួលពិធីជ្រមុជទឹក
2- ព្រះយេស៊ូប្រែទឹកឲ្យក្លាយជាស្រា
3- ព្រះយេស៊ូប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់
4- ព្រះជាម្ចាស់បង្ហាញសិរីរុងរឿងរបស់ព្រះយេស៊ូ
5- ព្រះយេស៊ូបូជាព្រះជន្មសម្រាប់មនុស្សលោក ។

## III. ព្រឹត្តិការណ៍នៃទុក្ខលំបាក

1- ព្រះយេស៊ូស្ថិតរន្ធត់នៅក្នុងសួនច្បារកេតសេម៉ានី
2- គេវាយព្រះយេស៊ូនឹងរំពាត់
3- គេបំពាក់មកុដបន្លាលើព្រះយេស៊ូ
4- គេឆ្កាងព្រះយេស៊ូ
5- ព្រះយេស៊ូសោយទិវង្គត ។

## IV. ព្រឹត្តិការណ៍សម្ដែងសិរីរុងរឿង

1- ព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង
2- ព្រះយេស៊ូយាងឡើងស្ថានបរមសុខ
3- ព្រះវិញ្ញាណយាងមកសណ្ឋិតលើក្រុមសាវ័ក
4- ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ
5- ព្រះជាម្ចាស់ប្រទានសិរីរុងរឿងឲ្យព្រះនាងម៉ារី ។

៩

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 60



## ព្រះសហគមន៍អធិដ្ឋានរួមជាមួយព្រះនាងម៉ារី

- បពិត្រព្រះនាងម៉ារី ពេលព្រះនាងអធិដ្ឋានថា៖ *«ព្រះអម្ចាស់បានសម្រេចការអស្ចារ្យចំពោះនាងខ្ញុំ»* ព្រះសហគមន៍ទាំងមូលក៏រួមអធិដ្ឋានជាមួយព្រះនាងដែរ ។
- ពិតមែន! *ព្រះអង្គបានសម្រេចការអស្ចារ្យ* មែន! គឺ ចំពោះព្រះអង្គ អ្នកតូចតាចមានតម្លៃខ្លាំងជាងគេ ហើយ ព្រះអង្គក៏រំដោះយើងឲ្យរួចពីចំណងនានាដែរ ។

៩

- ព្រះជាម្ចាស់នៃពិភពលោកទាំងមូល *បានសម្រេចការអស្ចារ្យ* មែន! ព្រះអង្គប្រោសជីវិតយើងឲ្យទៅជាពន្លឺផ្កាយដែលបំភ្លឺក្នុងលំហអាកាសវេហាស៍ ។
- *ព្រះអម្ចាស់បានសម្រេចការអស្ចារ្យ* មែន! គឺព្រះអង្គយកព្រះហឫទ័យទុកដាក់មកយើង ដោយទ្រង់ស្រឡាញ់យើង ។
- ព្រះអង្គប្រោសឲ្យយើងចម្រើនឡើង ដោយទ្រង់គង់នៅ ជាមួយយើងជារៀងរហូតតទៅ ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 61



## សូមក្រាបសំពះសម្តេចក្សត្រី ម៉ារី

- សូមក្រាបសំពះសម្តេចក្សត្រីម៉ារី
ជាព្រះមាតាដ៏មានធម៌មេត្តា ជាពុំនឹង
ហើយជាទីសង្ឃឹមរបស់យើង ។
យើងខ្ញុំជាកូនចៅអេវ៉ា នៅនាស្ថានដ៏លំបាកនេះ
ស្រែកដង្ហោយហៅព្រះនាង ។
កាលណាយើងខ្ញុំលាចាកលោកនេះទៅ
សូមព្រះនាងនាំយើងខ្ញុំ ឲ្យបានចូលរួមជាមួយព្រះយេស៊ូ
ជាព្រះបុត្រាដ៏ប្រសើររបស់ព្រះនាង ។

- ឱ! ព្រះនាងព្រហ្មចារិនីម៉ារី
ដ៏ពោរពេញដោយព្រះហឫទ័យ
មេត្តាករុណាប្រោសប្រណី
និងសុភាពរាបសា
សូមជួយអង្វរព្រះជាម្ចាស់
ឲ្យយើងខ្ញុំផង ។



Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 62

# ១០ សូមព្រះបិតា លើកលែងទោសឲ្យកូន



ឱ ព្រះបិតាអើយ !

១០ សូមប្រណីសន្ដោសកូនផង
ដ្បិតព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់
សូមលើកលែងទោសឲ្យកូនផង
ដ្បិតព្រះអង្គមានព្រះហឫទ័យមេត្តាដ៏ទូលំទូលាយ ។

ឱ ព្រះបិតាអើយ !

សូមកុំទតមើលអំពើបាបរបស់កូនឡើយ
តែសូមលុបបំបាត់កំហុសទាំងប៉ុន្មានរបស់កូនវិញ ។

*តាម ទន ៥១*

Petit Priere (31May11):Layout 1 6/9/2011 11:08 AM Page 63



## ខ្ញុំសូមទទួលសារភាព

ខ្ញុំសូមទទួលសារភាពចំពោះព្រះដ៏មានតេជានុភាពសព្វប្រការ
ហើយចំពោះអស់បងប្អូនផងថា
ខ្ញុំជាអ្នកមានបាបច្រើន ដោយកាយ វាចា ចិត្ត
និងដោយខានប្រព្រឹត្តកិច្ចការរបស់ខ្ញុំ
ទោសខ្ញុំអើយ ទោសខ្ញុំអើយ ទោសខ្ញុំអើយ ធ្ងន់ណាស់ ។
ហេតុនេះ សូមព្រះនាងព្រហ្មចារិនីម៉ារី អស់ទេវទូត
និង សន្តបុគ្គលទាំងឡាយ ព្រមទាំងអស់បងប្អូន
សូមជួយអង្វរព្រះអម្ចាស់ឲ្យខ្ញុំផង ។



## កូនសោកស្តាយណាស់

ព្រះជាម្ចាស់កូនអើយ !
កូនសោកស្តាយណាស់ដោយបានប្រព្រឹត្តអំពើបាប
ដែលមិនគាប់ព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គទ្រង់មេត្តាលើកលែងទោសឲ្យកូន
ហើយប្រទានកម្លាំងឲ្យកូន
ជៀសវាងអំពើបាបតរៀងទៅ ។ អាម៉ែន ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 64

# ១១ អធិដ្ឋានជូនអ្នកជំងឺ និងមរណបុគ្គល



## អធិដ្ឋានជូនអ្នកជំងឺធ្ងន់

១១ ទោះបីគ្រីស្តបរិស័ទមានជំនឿមាំមួនយ៉ាងណាក៏ដោយ ក៏នៅពេលជិតផុតដង្ហើម គេតែងតប់ប្រមល់ ឯបងប្អូនញាតិសន្តាន អ្នកជិតខាងក៏ព្រួយបារម្ភចំពោះគេវិញដែរ ។ ដូច្នេះគ្រីស្តបរិស័ទ គួរតែជួយលើកទឹកចិត្តអ្នកជិតផុតដង្ហើមកុំខានឲ្យសោះ ។

ក្នុងពេលនោះ ប្រសិនបើអាចធ្វើបាន គួរអានអត្ថបទគម្ពីរខ្លីៗ ដូចខាងក្រោម និងនិយាយពាក្យផ្អែមល្ហែមអំពីឪពុក អំពីម្ដាយ អំពីមិត្តសម្លាញ់ អំពីបងប្អូនដែលចែកស្ថានទៅហើយ ព្រមទាំងអំពីព្រះបិតាដែលចាំទទួលគាត់នៅឯស្ថានបរមសុខ ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 65



-ព្រះយេស៊ូមានព្រះបន្ទូលថា៖ «អ្នកណាពិសាសាច់ និង លោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំក៏នឹង ប្រោសគេឲ្យមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង ។

សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ លោហិតរបស់ខ្ញុំ ក៏ជាភេសជ្ជៈដ៏ពិតប្រាកដដែរ» ។ *(យហ ៦,៥៤-៥៥)*

-ព្រះយេស៊ូមានព្រះបន្ទូលថា៖ «អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ ។ ព្រះបិតាខ្ញុំនឹងស្រឡាញ់ អ្នកនោះ ហើយព្រះបិតានិងខ្ញុំក៏នឹងមកតាំងលំនៅ នៅក្នុង អ្នកនោះដែរ» ។ *(យហ ១៤,២៣)*

-«នៅឯព្រះបិតា ខ្ញុំមានដំណាក់ជាច្រើន បើពុំដូច្នេះទេ ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា ខ្ញុំទៅរៀបចំកន្លែងទុកឲ្យ អ្នករាល់គ្នាឡើយ ។ ពេលខ្ញុំរៀបចំកន្លែងទុកឲ្យអ្នករាល់គ្នា រួចហើយ ខ្ញុំនឹងត្រឡប់មកវិញ យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ ។ ឯកន្លែងដែលខ្ញុំទៅនោះ អ្នករាល់គ្នាក៏ស្គាល់ផ្លូវទៅដែរ» ។

*(យហ ១៤,២-៤)*

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 66



## ខ្ញុំឈឺធ្ងន់

- បពិត្រព្រះយេស៊ូជាអម្ចាស់
ខ្ញុំធ្លាក់ខ្លួនឈឺ ខ្ញុំអស់ទាំងកម្លាំងកាយ និងកម្លាំងចិត្តដែរ ។
ពេលនេះ ដូចអ្នកជំងឺឯទៀតៗ
គឺខ្ញុំតប់ប្រមល់ក្នុងចិត្តយ៉ាងខ្លាំង
ដោយមិនដឹងថាខ្លួននឹងទៅជាយ៉ាងណា?
ខ្ញុំព្រួយចិត្តខ្លាំងពិតមែន តែក៏មានបងប្អូនជាច្រើន
មកបោមរោម ដើម្បីលើកទឹកចិត្តខ្ញុំ ។

- ចំពោះព្រះអង្គវិញ ពេលរងទុក្ខលំបាកបែរជាមានមនុស្ស
មកបោមរោមវាយធ្វើបាប និងប្រមាថព្រះអង្គ ។

១១ - ឱ ព្រះយេស៊ូអើយ!
ខ្ញុំមិនសូមអង្វរព្រះអង្គប្រទានការអស្ចារ្យណាមួយ
ឬឲ្យខ្ញុំបានជាឡើយ តែខ្ញុំសូមឲ្យខ្លួនខ្ញុំស្ថិតនៅជាប់នឹង
ព្រះឫទ័យប្រណីសន្ដោសរបស់ព្រះអង្គគ្រប់ពេលវេលាវិញ
ដើម្បីឲ្យទុក្ខលំបាកទាំងអស់របស់ខ្ញុំ
បានរួមជាមួយនឹងទុក្ខលំបាករបស់ព្រះអង្គ ។

- បពិត្រព្រះយេស៊ូជាអម្ចាស់
  សូមប្រោសឲ្យខ្ញុំឈប់ភ័យខ្លាច
  សូមព្រះអង្គទទួលយកទុក្ខលំបាកពីខ្ញុំ
  សូមព្រះអង្គទទួលយកជីវិតរបស់ខ្ញុំ
  ឲ្យបានរួមក្នុងព្រះជន្មរបស់ព្រះអង្គផង ។

## **យើងអង្វរសម្រាប់អ្នកជំងឺ**

- បពិត្រព្រះយេស៊ូជាអម្ចាស់!
  ព្រះអង្គទទួលយកទុក្ខលំបាកពីយើងខ្ញុំ
  ព្រះអង្គក៏ទទួលយកការឈឺចាប់របស់យើងខ្ញុំដែរ ។
- សូមព្រះអង្គអាណិតអាសូរយើងខ្ញុំ
  ដែលរស់នៅសព្វថ្ងៃនេះផង!
  សូមព្រះអង្គអាណិតអាសូរដល់លោកតា/ លោកយាយ/
  មា/ មីង/ បង/ ប្អូន(ឈ្មោះ...)ដែលគាត់កំពុងឈ(ឈឺអ្វី?)
  គាត់អស់កម្លាំងយ៉ាងខ្លាំង ។ គាត់មានចិត្តជឿសង្ឃឹមលើ
  ព្រះអង្គ ដោយសារជំនឿនោះ សូមឲ្យគាត់មានចិត្តក្លាហាន
  មានសេចក្ដីសុខសាន្ត ដើម្បីបន្តដំណើរតទៅមុខទៀត ។
  បពិត្រព្រះយេស៊ូជាអម្ចាស់! សូមអាណិតអាសូរយើងខ្ញុំផង ។

១១

## យើងអង្វរសម្រាប់អ្នកជំងឺ

- បពិត្រព្រះអម្ចាស់ជាព្រះជាម្ចាស់និងជាព្រះបិតានៃយើងខ្ញុំ! ព្រះអង្គមិនលះបង់បោលសត្វលោកណាមួយ ដែលព្រះអង្គបង្កើតមក ឲ្យដាច់ចេញពី ព្រះហឫទ័យដ៏សប្បុរសរបស់ព្រះអង្គនោះឡើយ! ពេលនេះ សូមព្រះអង្គទតដោយព្រះហឫទ័យដ៏សប្បុរស ដល់លោកតា/ លោកយាយ/ មា/ មីង/ បង/ ប្អូន...(ឈ្មោះ) ដែលគាត់កំពុងឈឺ...(ឈឺអ្វី?)នេះផង ។
- សូមព្រះអង្គប្រទានកម្លាំង និងសេចក្ដីសង្ឃឹមដល់គាត់ ។
- សូមព្រះអង្គគង់នៅក្បែរ(ឈ្មោះ) ដើម្បីឲ្យគាត់មានចិត្តនឹងនរ ។

១១

- សូមព្រះអង្គប្រោសឲ្យគាត់មានចិត្តក្លាហាន និងឲ្យមានសេចក្ដីសុខសាន្ត ដើម្បីឲ្យទុក្ខលំបាករបស់គាត់បានរួមជាមួយនឹង ទុក្ខលំបាករបស់ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះអង្គ និងជាព្រះអម្ចាស់យើងខ្ញុំ ។

## ជូនព្រះកាយព្រះគ្រីស្ដដល់អ្នកជំងឺ

គ្រីស្ដបរិស័ទដែលនាំព្រះកាយព្រះគ្រីស្ដ គោរពអ្នកជំងឺ និងអ្នកនៅជុំវិញខ្លួន តាមរបៀបសាមញ្ញ និងភាតរភាព ។

***ទាំងអស់គ្នាច្រៀង***

"ទីណាមានមេត្តា" ឬ *"ព្រះគ្រីស្ដជាគង្វាលការពារខ្ញុំ "*
ឬ *"ព្រះជាម្ចាស់ទ្រង់ជាពន្លឺ "* ។

***សូមព្រះជាម្ចាស់រំដោះបាបឱ្យយើងខ្ញុំ***

*ខ្ញុំសូមទទួលសារភាព...* (ទំព័រ ៦៣)

***សូមអ្នកណែនាំអានអត្ថបទព្រះគម្ពីរមួយ នៅទំព័រ ៦៥***

***ពាក្យអង្វរ***

ឱ! ព្រះជាម្ចាស់អើយ យើងខ្ញុំសូមអង្វរព្រះអង្គ

- សម្រាប់អ្នកជំងឺឈ្មោះ ............... និងក្រុមគ្រួសារ
- សម្រាប់ក្មេងៗ និងអ្នកដែលរងគ្រោះថ្នាក់
- សម្រាប់គ្រូពេទ្យទាំងអស់
- សម្រាប់អស់អ្នកដែលរងទុក្ខលំបាកទាំងឡាយ
- សម្រាប់ ... ។

***ទទួលព្រះកាយព្រះគ្រីស្ត***

ដូចព្រះយេស៊ូប្រៀនប្រដៅយើងខ្ញុំ ហើយតាមបញ្ជារបស់ព្រះអង្គ យើងខ្ញុំហ៊ានសូត្រថា៖ **ឱ! ព្រះបិតាយើងខ្ញុំ** (ទំព័រ ៥)

- នេះជាព្រះកាយព្រះគ្រីស្ត ដែលរំដោះបាបមនុស្សលោកីយ៍ អស់អ្នកដែលទទួលព្រះកាយព្រះអង្គក្នុងពិធីជប់លៀងនេះ ពិតជាបានសុភមង្គល ។
- **ឱ! ព្រះអម្ចាស់អើយ ខ្ញុំមិនសមនឹងទទួលព្រះអង្គទេ តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក នោះព្រលឹងខ្ញុំនឹងជាសះស្បើយ ។** (ជូនព្រះកាយព្រះគ្រីស្ត)
- ព្រះកាយព្រះគ្រីស្ត
- **អាម៉ែន ។** (នៅស្ងៀមស្ងាត់បន្តិច)

**១១** ***សូមបងប្អូនតាំងចិត្តអធិដ្ឋាន***

- ឱ! ព្រះបិតាជាព្រះដ៏វិសុទ្ធប្រកបដោយតេជានុភាពសព្វប្រការ ដោយសារបងប្អូន...បានទទួលព្រះកាយព្រះលោហិតព្រះយេស៊ូគ្រីស្ត ដែលសោយរាជ្យអស់កល្បជានិច្ច យើងខ្ញុំសូមអង្វរព្រះអង្គ សូមឲ្យបងប្អូន...បានជាសះស្បើយ ជារៀងរហូត អាម៉ែន ។
- ច្រៀង៖ អស់មួយជីវិត ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 71



## អធិដ្ឋានសម្រាប់សព

ឱ! ព្រះបិតាជាអម្ចាស់យើងខ្ញុំ
សូមទ្រង់ព្រះមេត្តាទទួលព្រលឹង(បង/ប្អូន/មា/មីង ឈ្មោះ)
ដែលទើបនឹងចែកឋានអម្បាញ់មិញនេះ
សូមឲ្យគាត់បានពោរពេញដោយអំណរសប្បាយ
នៅឯស្ថានបរមសុខរួមជាមួយព្រះអង្គផង
ទោះបីគាត់បានប្រព្រឹត្តអំពើបាបយ៉ាងណាក្ដី
ក៏សូមទ្រង់ព្រះមេត្តាលើកលែងទោសឲ្យគាត់
តាមព្រះហឫទ័យមេត្តាករុណាដ៏លើសលុបរបស់ព្រះអង្គ ។
យើងខ្ញុំសូមអង្វរព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។ អាម៉ែន ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 72



## អធិដ្ឋានជូនគ្រីស្តបរិស័ទដែលទទួលមរណភាព

ឱ ព្រះបិតាជាអម្ចាស់ !
យើងខ្ញុំសូមផ្ញើជីវិតបង/ ប្អូន/ តា/ យាយ (ឈ្មោះ) របស់ខ្ញុំ
ដែលបានទទួលមរណភាពនេះ ទៅព្រះអង្គ
ដោយមានចិត្តសង្ឃឹមថា
អស់លោកអ្នកដែលបានជឿលើព្រះគ្រីស្ត
នឹងបានសម្រាកដោយសុខសាន្ត
ហើយនិងមានជីវិតរស់ឡើងវិញផង ។
សូមទ្រង់ព្រះមេត្តាពង្រឹងជំនឿរបស់យើងខ្ញុំ
និងប្រោសប្រទានឲ្យយើងខ្ញុំនៅថ្ងៃណាមួយ
រួមរស់ជាមួយបង/ ប្អូន/ តា/ យាយ (ឈ្មោះ)
ទាំងរួមជាមួយព្រះអង្គផង ។
យើងខ្ញុំសូមអង្វរព្រះបិតា តាមរយៈព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 73



## ពាក្យដាស់តឿនគ្រីស្តបរិស័ទ

អ្នកណែនាំពិធីអាចនិយាយពាក្យខាងក្រោមនេះ ឬពាក្យផ្សេងក៏បាន៖

- យើងជាគ្រីស្តបរិស័ទជួបជុំគ្នា
  ចូលរួមរំលែកទុក្ខលោក/អ្នកស្រី(ឈ្មោះ)
  ដែល(ឪពុក/ម្តាយ/បង/ប្អូន របស់គាត់)
  ទើបនឹងទទួលមរណភាព ។
- សូមព្រះជាអម្ចាស់សម្រាលទុក្ខ
  និងពង្រឹងជំនឿរបស់ពួកគាត់ក្នុងថ្ងៃដ៏សែនព្រួយនេះផង ។
  យើងក៏សូមព្រះអង្គទទួលវិញ្ញាណក្ខន្ធ (ឈ្មោះ...)
  ដែលបានចែកស្ថានទៅ ឲ្យបាននៅជាមួយព្រះអង្គ
  គឺឲ្យបានប្រកបដោយបរមសុខគ្រប់យ៉ាង
  តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។
- យើងខ្ញុំសូមអុជទៀននេះ ទុកជាសញ្ញាសម្គាល់
  បញ្ជាក់ពីជំនឿរបស់យើងខ្ញុំថា មនុស្សស្លាប់នឹងទទួលជីវិត
  រួមជាមួយព្រះគ្រីស្តអស់កល្បជានិច្ចវិញ ។
  «ឱ! ព្រះបិតា...បពិត្រព្រះនាងម៉ារី... សូមកោតសរសើរ...»

(ទំព័រ ៥-៦)

១១

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 74

# ១២ អធិដ្ឋានមុនពេលធ្វើដំណើរ



## សូមព្រះបិតាការពារយើងខ្ញុំ

១២

ឱ! ព្រះជាម្ចាស់អើយ! ក្នុងពេលធ្វើដំណើរនេះ
សូមព្រះអង្គមេត្តាណែនាំ និងការពារយើងខ្ញុំទាំងអស់គ្នា
ឲ្យរួចផុតពីឧបទ្រពចង្រៃ
ព្រមទាំងគ្រោះកំណាចទាំងឡាយផង ។ អាម៉ែន ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 75



## សូមព្រះបិតាប្រណីសន្ដោសយើងខ្ញុំ

- បពិត្រព្រះបិតាយើងខ្ញុំ
  ប្រកបដោយព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង!
- សូមព្រះអង្គជូនដំណើរយើងខ្ញុំ
  ឲ្យបានដល់ទីដៅដោយសេចក្ដីសុខសាន្ត ។
- សូមព្រះបិតាការពារយើងខ្ញុំ
  កុំឲ្យមានគ្រោះថ្នាក់ កុំឲ្យមានទុក្ខព្រួយអ្វីឡើយ ។
- សូមព្រះអង្គអាណិតអាសូរយើងខ្ញុំ
  សូមព្រះអង្គមេត្តាស្ដាប់ពាក្យអង្វររបស់យើងខ្ញុំ ។
- សូមកោតសរសើរព្រះបិតាជាអម្ចាស់
  សូមព្រះអម្ចាស់ប្រទានពរ និងថែរក្សាយើងខ្ញុំ ។
- សូមព្រះអង្គទតមកយើងខ្ញុំ ដោយព្រះហឫទ័យមេត្តាករុណា
  សូមព្រះអង្គប្រណីសន្ដោសយើងខ្ញុំ ។
- សូមព្រះអម្ចាស់សម្ដែងព្រះហឫទ័យសប្បុរសចំពោះយើងខ្ញុំ
  និងប្រទានឲ្យយើងខ្ញុំបានប្រកបដោយសេចក្ដីសុខសាន្តផង ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 76



## ព្រះជាម្ចាស់ស្រឡាញ់យើង

ព្រះជាម្ចាស់ស្រឡាញ់យើង ព្រះអង្គគង់ជាមួយយើង
នៅទីណាក៏មិនខ្លាច ទៅឆ្ងាយក៏មិនភ័យ
ព្រោះព្រះជាម្ចាស់ស្រឡាញ់យើង ។

## ចូរនាំគ្នាទៅ

ចូរនាំគ្នាទៅគ្រប់ទីកន្លែង ក្នុងពិភពលោកទាំមូល
ហើយប្រកាសដំណឹងល្អ ដល់មនុស្សទាំងអស់ ។

១២

## ទីណាមានមេត្តា

ទីណាមានមេត្តា និងក្ដីស្រឡាញ់
ទីណាមានមេត្តា ព្រះជាម្ចាស់គង់ជាមួយយើង ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 77

# ១៣ ធម៌ប្រកាសជំនឿផ្សេងៗ



## ប្រកាសជំនឿរបស់គ្រីស្តទូតទាំងឡាយ

- ***ខ្ញុំជឿ*** *លើព្រះបិតាដ៏មានតេជានុភាពសព្វប្រការ*
  *ជាព្រះបង្កើត មេឃ និងដី ។*
- **ខ្ញុំជឿ** លើព្រះយេស៊ូគ្រីស្ត
  ជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់យើងខ្ញុំ ។

១៣

ព្រះអង្គបានចាប់កំណើតជាមនុស្សដោយសារព្រះវិញ្ញាណ
ដ៏វិសុទ្ធ ហើយទ្រង់បានប្រសូត ពីព្រះនាងព្រហ្មចារិនីម៉ារី
ព្រះអង្គបានសោយទុក្ខលំបាកនៅជំនាន់លោកប៉ុនពីឡាត ។
ព្រះអង្គត្រូវគេឆ្កាង សោយព្រះទិវង្គត
ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ ។
ព្រះអង្គបានយាងចុះទៅស្ថានក្រោម
លុះដល់ថ្ងៃទី ៣ ទ្រង់មានព្រះជន្មរស់ឡើងវិញ
រួចព្រះអង្គបានយាងឡើងស្ថានបរមសុខ
ទៅគង់ខាងស្តាំព្រះបិតាដ៏មានតេជានុភាពសព្វប្រការ ។
ព្រះអង្គបានយាងមកវិញ ដើម្បីកាត់ក្តីបាបកុសលឲ្យមនុស្ស
ទាំងរស់ ទាំងស្លាប់ ។

- ***ខ្ញុំជឿ****លើព្រះវិញ្ញាណដ៏វិសុទ្ធ*
  ***ខ្ញុំជឿ****លើព្រះសហគមន៍កាតូលិក និងសហភាពរវាង*
  *ជនដ៏វិសុទ្ធទាំងឡាយ*
  ***ខ្ញុំជឿ****ថា មានការលើកលែងទោសរំដោះបាប ហើយ*
  *រូបកាយមនុស្សនឹងរស់ឡើងវិញ ព្រមទាំងមានជីវិត*
  *រស់នៅអស់កល្ប ជានិច្ចផង ។ អាម៉ែន ។*

១៣

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 79



## ខ្ញុំជឿពិតប្រាកដលើព្រះត្រៃឯក

ឱ! ព្រះជាអម្ចាស់អើយ!
**ខ្ញុំជឿ**លើព្រះបិតា
ដែលទ្រង់ស្រឡាញ់អស់មនុស្សទាំងឡាយ ។
**ខ្ញុំជឿ**លើព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ
ដែលទ្រង់សង្គ្រោះមនុស្សលោក ។
**ខ្ញុំជឿ**លើព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់ជាមួយយើងខ្ញុំ
ហើយណែនាំយើងខ្ញុំ ក្នុងព្រះសហគមន៍ព្រះអង្គ ។

## ខ្ញុំសង្ឃឹមលើព្រះជាម្ចាស់

ឱ ព្រះជាម្ចាស់ខ្ញុំអើយ!
ខ្ញុំសង្ឃឹមយ៉ាងមាំលើព្រះអង្គ
ដែលទ្រង់ជួយដឹកនាំការពារខ្ញុំគ្រប់ពេលវេលា
ហើយនឹងប្រទានឲ្យខ្ញុំបានចូលរួមជាមួយព្រះយេស៊ូគ្រីស្ត
នាថ្ងៃព្រះអង្គយាងមកវិញ
តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ។

Petit Priere (31May11):Layout 1 6/6/2011 11:08 AM Page 80



## សូមព្រះអម្ចាស់លើកលែងទោស

ឱ ព្រះអម្ចាស់អើយ !
ខ្ញុំសោកស្ដាយណាស់
ដោយបានធ្វើបាបខុសនឹងព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គទ្រង់ព្រះមេត្តាលើកលែងទោសឲ្យខ្ញុំ
ហើយប្រទានឲ្យខ្ញុំមានកម្លាំងជៀសវាងអំពើបាបតរៀងទៅ ។
អាម៉ែន ។

## ខ្ញុំស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត

ឱ ព្រះជាម្ចាស់ខ្ញុំអើយ !
ខ្ញុំស្រឡាញ់ព្រះអង្គអស់ពីដួងចិត្ត និងលើសអ្វីៗទាំងអស់
ដ្បិតព្រះអង្គមានព្រះហឫទ័យសប្បុរសយ៉ាងក្រៃលែង
១៣ ខ្ញុំស្រឡាញ់បងប្អូនឯទៀតៗ ដូចស្រឡាញ់ខ្លួនឯង
តាមព្រះបន្ទូលរបស់ព្រះអង្គ ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 81



## យើងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់

សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏
ខ្ពង់ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់
របស់ព្រះអង្គ បានសេចក្ដីសុខសាន្ត ។

*យើងខ្ញុំសូមលើកតម្កើងព្រះអង្គ កោតសរសើរព្រះអង្គ*
*ក្រាបប្រណិប័តន៍ព្រះអង្គ ថ្វាយបង្គំព្រះអង្គ អរព្រះគុណព្រះអង្គ*
*ដែលប្រកបដោយសិរីរុងរឿងដ៏ធំទូលំទូលាយ ។*

ឱ! ព្រះជាម្ចាស់ជាស្ដេចស្ថានបរមសុខ
ហើយជាព្រះបិតា ដ៏មានតេជានុភាពសព្វប្រការ ។

*ឱ! ព្រះយេស៊ូគ្រីស្ដជាអម្ចាស់ជាព្រះបុត្រាតែមួយរបស់ព្រះបិតា*
*ព្រះអង្គពិតជាព្រះម្ចាស់ ជាកូនចៀមព្រះជាម្ចាស់*
*ហើយជាព្រះបុត្រានៃព្រះបិតាផង ។*

១៣

សូមព្រះអង្គរំដោះបាបមនុស្សលោកីយ៍
សូមអាណិតអាសូរយើងខ្ញុំ
សូមព្រះអង្គរំដោះបាបមនុស្សលោកីយ៍

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 82



*សូមទទួលពាក្យអង្វរយើងខ្ញុំ*
*សូមព្រះអង្គដែលគង់ខាងស្ដាំព្រះបិតា*
*សូមអាណិតអាសូរយើងខ្ញុំ ។*

ឱ ព្រះយេស៊ូគ្រីស្ដអើយ!
មានតែព្រះអង្គទេជាព្រះដ៏វិសុទ្ធ
ជាព្រះអម្ចាស់  ហើយជាព្រះដ៏ឧត្ដមបំផុត
ព្រះអង្គគង់នៅជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ
ក្នុងសិរីរុងរឿងនៃព្រះបិតា ។  អាម៉ែន ។



១៣

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 83

# ១៨ អរព្រះគុណព្រះបិតា ចំពោះទេវទូត



ឱ! ទេវទូតនៃព្រះជាម្ចាស់ជាអ្នកការពារជាទីស្រឡាញ់
របស់ខ្ញុំអើយ ដោយព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់
ព្រះអង្គបានចាត់លោកឲ្យមកមើលថែខ្ញុំ ។ នៅថ្ងៃនេះ សូម
លោកនៅក្បែររូបខ្ញុំដើម្បីបំភ្លឺ និងការពារខ្ញុំ ដើម្បីគ្រប់គ្រង
និងណែនាំខ្ញុំ ។ អាម៉ែន ។

## សូមកោតសរសើរព្រះបិតា

- បពិត្រព្រះអម្ចាស់ជាព្រះបិតា!
  កូនសូមកោតសរសើរព្រះប្រាជ្ញាញាណព្រះអង្គ
  ដែលបាត់ចែងមុខងារផ្សេងៗ
  ឲ្យទេវទូត និងឲ្យមនុស្សលោកបំពេញ ។
  សូមព្រះអង្គថែរក្សាកូនដែលរស់នៅលើផែនដីនេះ ។
  សូមប្រោសកូនឲ្យយកចិត្តទុកដាក់
  នឹងសញ្ញាសម្គាល់របស់ព្រះអង្គក្នុងលោកនេះផង ។

**********

## ទេវទូតជួយថែរក្សាការពារយើងខ្ញុំ

ឱ! ព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំអើយ!
ដោយសារសេចក្ដីស្រឡាញ់របស់ព្រះអង្គ
ទ្រង់បានបាត់ទេវទូតមកជួយថែរក្សា
ការពារយើងខ្ញុំទាំងអស់គ្នា ។ សូមជួយការពារយើងខ្ញុំ
១៤ សូមឲ្យយើងខ្ញុំបានចូលរួមជាមួយទេវទូត
ដើម្បីលើកតម្កើងព្រះអង្គអស់កល្បជាអង្វែងតរៀងទៅ ។
អាម៉ែន ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 85



## ទេវទូតការពារយើងខ្ញុំ

- បពិត្រព្រះអម្ចាស់ជាព្រះបិតា!
  យើងខ្ញុំសូមទូលព្រះអង្គថា៖
  ព្រះអង្គជាជម្រក និងជាកំពែងការពារយើងខ្ញុំ
  ព្រះអង្គជាព្រះនៃយើងខ្ញុំ
  យើងខ្ញុំសូមផ្ញើជីវិតលើព្រះអង្គ ។

- ព្រះអម្ចាស់ជាជម្រករបស់យើងខ្ញុំ
  យើងខ្ញុំបានមកជ្រកកោន
  ក្រោមម្លប់របស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត ។
  គ្មានទុក្ខវេទនាណាមួយកើតមានដល់យើងខ្ញុំបានឡើយ
  ហើយក៏គ្មានគ្រោះកាចណាមួយ
  ចូលទៅជិតទីលំនៅរបស់យើងខ្ញុំបានដែរ
  ដ្បិតព្រះអម្ចាស់បញ្ជាឲ្យពួកទេវទូតជួយយើងខ្ញុំ ។

- ពួកទេវទូតការពារយើងខ្ញុំ
  នៅគ្រប់ទីកន្លែងដែលយើងខ្ញុំទៅ ។
  ទេវទូតទាំងនោះនឹងចាំទ្រយើងខ្ញុំ
  មិនឲ្យជើងយើងខ្ញុំប៉ះទង្គិចនឹងថ្មឡើយ ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 86

# ១៥ អធិដ្ឋានសកល




## សូមព្រះបិតាប្រោសប្រទានឱ្យកូនសាងសន្តិភាព

*- ពេលណាមានមនុស្សកើតទុក្ខព្រួយ*
*ពេលនោះសូមឲ្យកូនជួយគេ ឲ្យមានអំណរសប្បាយ ។*
*- ពេលណាយើងលះបង់ប្រយោជន៍ផ្ទាល់ខ្លួន*
*ពេលនោះ យើងទទួលប្រយោជន៍វិញ ។*

១៥

- ពេលណាយើងលើកលែងទោសឲ្យអ្នកដទៃ
  ពេលនោះ ព្រះជាម្ចាស់នឹងលើកលែងទោសឲ្យយើងវិញ ។
- ពេលណាយើងបាត់បង់ជីវិតក្នុងលោកនេះ ពេលនោះ
  យើងនឹងមានជីវិតរស់ឡើងវិញ រួមជាមួយព្រះអង្គជានិច្ច ។

  - ទីណាមានមនុស្សស្អប់គ្នា
    ទីនោះសូមឲ្យកូនផ្តល់សេចក្តីស្រឡាញ់ ។
  - ទីណាមានមនុស្សប្រទូស្តរ៉ាយគ្នា ទីនោះសូម
    ឲ្យកូនជួយគេ ឲ្យលើកលែងទោសគ្នាទៅវិញទៅមក ។

- ទីណាមានមនុស្សបាក់បែកគ្នា
  ទីនោះសូមឲ្យកូនជួយគេ ឲ្យស្រុះស្រួលគ្នា ។
- ទីណាមានមនុស្សមន្ទិលសង្ស័យ
  ទីនោះសូមឲ្យកូនជួយគេឲ្យមានទំនុកចិត្ត ។

  - *ទីណាមានមនុស្សបាត់ក្តីសង្ឃឹម*
    *ទីនោះសូមឲ្យកូនជួយគេ ឲ្យមានសង្ឃឹម ។*
  - *ទីណាមានមនុស្សដើរក្នុងផ្លូវងងឹត*
    *ទីនោះសូមឲ្យកូនផ្តល់ពន្លឺ ។*

*អ្នកម្តាយតេរេសា*

## សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះសហគមន៏

- បពិត្រព្រះបិតា !
  ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង!
  ព្រះអង្គបានប្រោសមនុស្សលោកទាំងអស់
  ឲ្យបានស្គាល់ព្រះអង្គដោយសារព្រះគ្រីស្ត ។
- សូមទ្រង់ព្រះមេត្តាអាណិតអាសូរដល់ព្រះសហគមន៍
  ដែលកើតមកពីធម៌មេត្តាករុណារបស់ព្រះអង្គ ។
- សូមប្រោសព្រះសហគមន៍ក្នុងពិភពលោកទាំងមូល
  ឲ្យកាន់ជំនឿតែមួយយ៉ាងរឹងមាំផង ។
- យើងខ្ញុំសូមអង្វរព្រះអង្គ
  ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត
  ជាព្រះអម្ចាស់យើង ខ្ញុំ ។ អាម៉ែន ។

## ធម៌របស់សន្ដៈហ្វ្រង់ស្វ័រនៅអាស៊ីស៊ី

ឱ ព្រះជាអម្ចាស់ !
សូមឲ្យខ្ញុំយកចិត្តទុកដាក់រំលែកទុក្ខអ្នកឯទៀត
ជាជាងឲ្យគេរំលែកទុក្ខខ្ញុំ ។
សូមឲ្យខ្ញុំចេះយល់ចិត្តអ្នកឯទៀត
ជាជាងឲ្យគេយល់ចិត្តខ្ញុំ ។
សូមឲ្យខ្ញុំស្រឡាញ់អ្នកឯទៀត
ជាជាងឲ្យគេស្រឡាញ់ខ្ញុំ ។

*ដ្បិតពេលណាយើងស្ម័គ្រចិត្តបូជាជីវិត*
*ពេលនោះ យើងទទួលជីវិតវិញ ។*
*ដ្បិតពេលណាយើងលះបង់ប្រយោជន៍ផ្ទាល់ខ្លួន*
*ពេលនោះ យើងទទួលប្រយោជន៍វិញ ។*

ដ្បិតពេលណាយើងអត់ទោសឲ្យអ្នកដទៃ ពេលនោះ
ព្រះជាអម្ចាស់នឹងលើកលែងទោសឲ្យយើងវិញដែរ ។
ដ្បិតពេលណាយើងចាកចេញពីលោកនេះទៅ
ពេលនោះ យើងនឹងមានជីវិតរស់អស់កល្បជានិច្ច ។

១៥

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 90



## សូមអង្វរព្រះជាម្ចាស់

*បន្ទរៈ កូនសូមស្រែកទូល អស់ពីដួងចិត្ត សូមព្រះអម្ចាស់ ស្តាប់សម្លេងកូន ។*

*- បពិត្រព្រះបិតាជាព្រះអម្ចាស់ !*
*សូមព្រះអង្គអាណិតអាសូរដល់ព្រះសហគមន៍ព្រះអង្គ*
*សូមឲ្យព្រះសហគមន៍រីកចម្រើនឡើង*
*ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ។*

- សូមឲ្យមនុស្សគ្រប់ជាតិសាសន៍
ទទួលស្គាល់ថា មានតែព្រះបិតាទេ
ដែលជាព្រះជាម្ចាស់ដ៏ពិតប្រាកដតែមួយព្រះអង្គ ។
សូមឲ្យមនុស្សលោកទទួលស្គាល់ព្រះយេស៊ូ
ទុកជាព្រះសង្គ្រោះរបស់ពួកគេផង ។

*- សូមព្រះអង្គប្រទានពរឲ្យអស់អ្នកដែលយើងខ្ញុំស្រឡាញ់ ។*
*សូមណែនាំគេឲ្យបានស្គាល់ព្រះអង្គកាន់តែច្បាស់ឡើងៗ ។*
*សូមព្រះអង្គប្រោសប្រណីដល់អស់អ្នកដែលបែកឋាន*
*ទៅហើយ ឲ្យបានឃើញព្រះភក្ត្រព្រះអង្គផង ។*

១៥
- សូមទ្រង់មេត្តាប្រោសនៅថ្ងៃណាមួយ
ឲ្យយើងខ្ញុំទទួលសុភមង្គលរួមជាមួយព្រះអង្គផង ។

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 91



## ពាក្យអង្វរសកល

- បពិត្រព្រះបិតាជាអម្ចាស់ យើងខ្ញុំសូមអរព្រះគុណព្រះអង្គ
  ដែលបានចាត់ព្រះយេស៊ូជាព្រះបុត្រា
  ឲ្យយាងមកបំភ្លឺយើងខ្ញុំ ។

*បន្ទរ៖ ឱ ព្រះជាម្ចាស់ កូនសូមអង្វរ សូមផ្ទៀងព្រះកាណ៌*
*ស្ដាប់ពាក្យកូនផង ដោយអនុគ្រោះ សូមប្រោសប្រណី ។*

- សូមឲ្យពន្លឺព្រះគ្រីស្ត
  នាំឲ្យយើងបានអំណរសប្បាយ ពេញមួយថ្ងៃនេះ ។
  - *សូមព្រះអង្គបង្ហាញធម៌មេត្តាករុណា*
    *ក្នុងគ្រប់កិច្ចការទាំងអស់*
    *ដែលយើងខ្ញុំប្រព្រឹត្តនៅថ្ងៃនេះ ។*
- សូមឲ្យយើងខ្ញុំឃើញសិរីរុងរឿងរបស់ព្រះអង្គ
  តាមរយៈមនុស្សគ្រប់ៗរូប ដែលយើងខ្ញុំជួបនៅថ្ងៃនេះ ។
  - *សូមព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំបំពេញការងារ*
    *បានសមរម្យតាមព្រះហឫទ័យរបស់ព្រះអង្គ ។*
- សូមឲ្យយើងខ្ញុំទៅជាអ្នកបម្រើដ៏ស្មោះត្រង់
  សូមព្រះអង្គប្រោសប្រណីយើងខ្ញុំផង ។

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 92



## ព្រះយេស៊ូជាព្រះអម្ចាស់

- បពិត្រព្រះយេស៊ូជាអម្ចាស់!
  សូមព្រះអង្គទតមើលអស់បងប្អូនដែលរស់នៅតាមតំបន់ព្រៃភ្នំ
  គឺអស់បងប្អូនរស់នៅក្នុងកុលសម្ព័ន្ធនានាផង ។
  សូមព្រះអង្គប្រទាន
  ឲ្យគេមានអាហារទទួលទានជារៀងរាល់ថ្ងៃ
  និងសូមឲ្យគេរួបរួមគ្នា ទុកគ្នាជាបងប្អូន ។
  - *បពិត្រព្រះយេស៊ូជាអម្ចាស់!*
    *សូមព្រះអង្គទតមើលអស់បងប្អូនដែលរស់នៅរបាត់របាយ*
    *តាមតំបន់ឆ្នេរនៃមហាសមុទ្រទាំងឡាយ ។*
    *សូមព្រះអង្គប្រទានឲ្យរបរនេសាទរបស់គេ*
    *អាចចិញ្ចឹមជីវិតបាន សូមឲ្យគេចេះរួបរួមគ្នាជាធ្លុងតែមួយ*
    *និងចេះរាក់ទាក់គ្នាផង ។*
- បពិត្រព្រះយេស៊ូជាអម្ចាស់! សូមព្រះអង្គទតមើលអស់បងប្អូន
  ដែលធ្វើការយ៉ាងហត់នឿយនៅក្រោមកម្ដៅនៃព្រះអាទិត្យ
  សូមឲ្យរបរកសិកម្មរបស់គេបានផលច្រើនអនេក
  ត្រឡប់ទៅជាអាហារអាចចិញ្ចឹមជីវិតមនុស្សលោកផង ។

១៥

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 93



- *បពិត្រព្រះយេស៊ូជាអម្ចាស់! សូមព្រះអង្គទតមើល អស់បងប្អូនកម្មករ ពលករទាំងឡាយផង សូមឲ្យពួកគេមានអាហារបរិភោគជារៀងរាល់ថ្ងៃ ។*

- បពិត្រព្រះយេស៊ូជាអម្ចាស់! សូមព្រះអង្គទតមើលអស់បងប្អូនកសិករ ដែលបានទទួលផលកសិកម្មពេញជង្រុករបស់ខ្លួន ។ សូមឲ្យគេចេះចែករំលែកភោគផលដែលបានទទួលពីព្រះអង្គ ដល់ជនខ្វះខាតទាំងឡាយផង ។

- *បពិត្រព្រះយេស៊ូជាអម្ចាស់! សូមព្រះអង្គប្រោសឲ្យ ប្រជាជននៅទ្វីបអាហ្វ្រិក នៅទ្វីបអូសេអានី នៅទ្វីបអាស៊ី នៅទ្វីបអឺរ៉ុប និងនៅទ្វីបអាមេរិក រួមគ្នាក្នុងព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គផង ។*

១៥

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 94



## សូមព្រះជាម្ចាស់ប្រទានពរដល់អស់លោកអ្នកដឹកនាំ

- បពិត្រព្រះបិតាប្រកបដោយតេជានុភាពសព្វប្រការ និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច! ព្រះអង្គឈ្វេងយល់ចិត្តគំនិតមនុស្សទាំងអស់ ហើយទ្រង់តែងការពារសិទ្ធិសិរីភាពប្រជាជនទាំងឡាយ ។

- សូមទ្រង់ព្រះមេត្តាប្រោសអស់លោកអ្នកដឹកនាំប្រទេសនានា ឲ្យខិតខំស្វែងរកប្រយោជន៍រួម ខិតខំស្វែងរកសន្តិភាព និងស្វែងរកសេចក្ដីសុខសាន្តនៅលើផែនដីទាំងមូល ។ សូមឲ្យអស់ លោកអ្នកគោរពសិទ្ធិសិរីភាពខាងជំនឿរបស់ប្រជាជនទាំងឡាយផង ។ អាម៉ែន ។



Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 95

ធម៌ ឱ! ព្រះបិតា ជាភាសាឡាតាំង

*Pater noster, qui es in cxlis:*
*sanctificetur nomen tuum; adveniat regnum tuum;*
*fiat voluntas tua, sicut in cxlis et in terria.*
*Panem nostrum quotdianum da nobis hodie;*
*et dimitte nobis debita nostra,*
*sicut et nos dimittimus debitoribus nostris;*
*et ne nos induscas in tentationem;*
*sed libera nos a Malo.*

ធម៌ បពិត្រព្រះនាងម៉ារី ជាភាសាឡាតាំង

*Ave Maria gratia plena,*
*Dominus tecum,*
*benedicta tu in mulieribus,*
*et benedictus fructus ventris tui, Iesus.*
*Sancta Maria mater Dei,*
*ora pro nobis peccatoribus,*
*nunc et in hora mortis nostrae. Amen.*

សូមកោតសរសើរជាភាសាឡាតាំង

*Gloria patria et filio et spiritus sancto*
*Sicut erat in principio et nunc et simper*
*et in saecula saeculorum, Amen.*

Petit Priere (31May11):Layout 1 6/2/2011 11:08 AM Page 96

# សូមបងប្អូនសរសេរពាក្យអធិដ្ឋានដែលខ្លួនពេញចិត្ត

# មាតិកា

- តើអធិដ្ឋានគឺអ្វី? ..........................................១

**១. អធិដ្ឋានពេលភ្ញាក់ពីដំណេក** - សូមថ្វាយខ្លួន ....................២

**២. អធិដ្ឋានពេលព្រឹក ...៤** - ឱ! ព្រះបិតាយើងខ្ញុំ ..................៥

- សូមអង្វរព្រះនាងម៉ារី - សូមកោតសរសើរ....................៦
- សូមអរព្រះគុណព្រះបិតា ....................................៧
- សូមអង្វរសម្រាប់ថ្ងៃថ្មី.........................................៨
- ព្រះយេស៊ូជាព្រះអម្ចាស់........................................៩

**៣. អធិដ្ឋានពេលល្ងាច...........................................១០**

- សូមថ្វាយកិច្ចការទាំងអស់របស់សត្វលោក....................១១
- សូមប្រទានសេចក្ដីសុខសាន្ត....................................១២
- សូមព្រះយេស៊ូគង់នៅជាមួយខ្ញុំ................................១៣
- ព្រះបិតាជាជម្រករបស់ខ្ញុំ .......................................១៤
- ព្រះបិតាគង់នៅជាមួយខ្ញុំ .......................................១៥
- អធិដ្ឋានរួមក្នុងគ្រួសារ...........................................១៦
- សូមអរព្រះគុណព្រះបិតា........................................១៨
- សូមព្រះអម្ចាស់បំភ្លឺចិត្តគំនិតកូន! ...............................១៩

**៤. អធិដ្ឋានពេលទទួលទានអាហារ ................................២០**

Petit Priere (31May11):Layout 1 6/?/2011 11:08 AM Page 98

**៥. ខ្ញុំសូមអរព្រះគុណព្រះបិតា** - អធិដ្ឋានរួមជាមួយព្រះនាងម៉ារី..២៤
- កូនស្រឡាញ់ព្រះបិតា ........................................២៦
- សូមកោតសរសើរព្រះអម្ចាស់..................................២៨
- កូនសូមលះបង់ខ្លួន ថ្វាយព្រះអង្គ ..............................៣០

**៦. សូមកោតសរសើរព្រះយេស៊ូ.......................................៣២**
- ព្រះគ្រីស្ដបន្ទាបព្រះកាយ និងទទួលសិរីរុងរឿង.............៣៣
- សូមកោតសរសើរព្រះយេស៊ូគ្រីស្ដ...............................៣៤
- ចូរនឹកដល់ព្រះយេស៊ូគ្រីស្ដ....................................៣៦
- ព្រះយេស៊ូសូមកុំភ្លេចខ្ញុំ.........................................៣៧
- ចូរនឹកដល់ព្រះយេស៊ូគ្រីស្ដ....................................៣៨

**៧. លើកតម្កើងអគ្គសញ្ញាដ៏វិសុទ្ធ.....................................៤០**
- គោរពព្រះកាយ ព្រះលោហិតព្រះគ្រីស្ដ .........................៤០
- សូមលើកតម្កើងអគ្គសញ្ញាដ៏វិសុទ្ធ ..............................៤១
- សូមគោរពអគ្គសញ្ញាដ៏វិសុទ្ធ- យើងលើកតម្កើងព្រះបិតា..៤២
- សូមលើកតម្កើងព្រះជាម្ចាស់....................................៤៣
- ព្រះអម្ចាស់យេស៊ូ ផ្ដល់ជីវិតឲ្យយើង ............................៤៤
- សូមកោតសរសើរ ...............................................៤៥

**៨. កូនអង្វរព្រះវិញ្ញាណ** - សូមយាងមក ឱ ព្រះវិញ្ញាណ! .........៤៦
- ភ្លើងនៃក្ដីស្រឡាញ់ - សូមអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ.........៤៧
- សូមអង្វរព្រះវិញ្ញាណ...........................................៤៨

**៩. កូននីករញ្ញកនិងអរគុណព្រះនាងម៉ារី ............................៥០**
- សូមពឹងផ្អែកលើព្រះនាងម៉ារី-សូមព្រះនាងម៉ារីទទួលយើង.៥២
- ព្រះនាងព្រហ្មចារិនីម៉ារី......................................៥៣
- ទេវទូតជូនដំណឹងព្រះនាងម៉ារី..................................៥៤
- សម្តេចក្សត្រីនៃស្ថានបរមសុខ..................................៥៦
- អធិដ្ឋានតាមមាលា..........................................៥៨
- ព្រះសហគមន៍អធិដ្ឋានរួមនៅជាមួយព្រះនាងម៉ារី..........៦០
- សូមក្រាបសំពះសម្តេចក្សត្រី ម៉ារី..............................៦១

**១០. សូមព្រះបិតាលើកលែងទោសឲ្យកូន.............................៦២**
- ខ្ញុំសូមទទួលសារភាព - កូនសោកស្តាយណាស់ ..............៦៣

**១១. អធិដ្ឋានជូនអ្នកជំងឺ និងមរណបុគ្គល** - អធិដ្ឋានជូន.........៦៤
- ខ្ញុំឈឺធ្ងន់........................................................៦៦
- យើងអង្វរសម្រាប់អ្នកជំងឺ......................................៦៧
- យើងអង្វរសម្រាប់អ្នកជំងឺ .....................................៦៨
- ជូនព្រះកាយព្រះគ្រីស្តដល់អ្នកជំងឺ...........................៦៩
- អធិដ្ឋានសម្រាប់សព..........................................៧១
- អធិដ្ឋានជូនគ្រីស្តបរិស័ទដែលទទួលមរណភាព ............៧២
- ពាក្យជាស់តឿនគ្រីស្តបរិស័ទ...................................៧៣

**១២. អធិដ្ឋានមុនពេលធ្វើដំណើរ** - សូមព្រះបិតាការពារយើងខ្ញុំ.៧៤
- សូមព្រះបិតាប្រណីសន្តោសយើងខ្ញុំ ...........................៧៥

- ព្រះជាម្ចាស់ស្រឡាញ់យើង- ចូរនាំគ្នាទៅ- ទីណាមានមេត្តា.៧៦

**១៣.ធម៌ប្រកាសជំនឿផ្សេងៗ**- ប្រកា.របស់គ្រីស្តទូតទាំងឡាយ..៧៧

- ខ្ញុំជឿពិតប្រាកដលើព្រះត្រៃឯក- ខ្ញុំសង្ឃឹមលើព្រះជាម្ចាស់.៧៩
- ខ្ញុំសូមព្រះអម្ចាស់លើកលែងទោស ..............................៨០
- ខ្ញុំស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត ..........................៨០
- យើងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់.............៨១

**១៤. អរព្រះគុណព្រះបិតាចំពោះទេវទូត..............................៨៣**

- សូមកោតសរសើរព្រះបិតា -ទេវទូតជួយថែរក្សាយើងខ្ញុំ.៨៤
- ទេវទូតការពារយើងខ្ញុំ.......................................៨៥

**១៥. អធិដ្ឋានសកល.....................................................៨៦**

- សូមព្រះបិតាប្រោសប្រទានឲ្យកូនសាងសន្តិភាព.............៨៧
- សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះសហគមន៍...............៨៨
- ធម៌របស់សន្តៈហ្វ្រង់ស្វ័រនៅអាស៊ីស៊ី .............................៨៩
- សូមអង្វរព្រះជាម្ចាស់.........................................៩០
- ពាក្យអង្វរសកល ..............................................៩១
- ព្រះអម្ចាស់ប្រទានពរដល់អស់អ្នកកើតទុក្ខព្រួយ ..........៩២
- សូមអង្វរព្រះជាម្ចាស់ប្រទានពរដល់អស់លោកអ្នកដឹកនាំ ប្រទេសនានា ..............................................................៩៤
- ឱព្រះបិតា-ព្រះនាងម៉ារី- កោតសរសើរ (ភាសាឡាតាំង) ....៩៥

***********